## កិច្ចរបស់ចិត្ត ១៤

- បដិសន្ធិកិច្ច
- ភវង្គកិច្ច
- អាវជ្ជនកិច្ច
- ទស្សនកិច្ច
- សវនកិច្ច
- ឃាយនកិច្ច
- សាយនកិច្ច
- ផុស្សនកិច្ច
- សម្បដិច្ឆន្នកិច្ច
- សន្តីរណកិច្ច
- វោដ្ឋព្វនកិច្ច
- ជវនកិច្ច
- តទាលម្ពណកិច្ច
- ចុតិកិច្ច

# មហាសុបិន ១៦ ប្រការ

ពុទ្ធសករាជ ២៥៤៨

ហាយ ចំរើន

# អារម្ភកថា

រឿងរ៉ាវក្នុងលោក ព្រោះតែការសន្មត់ មានច្រើនសន្ធឹកសន្ធាប់ណាស់ រហូតមិនអាចនឹងគិតបាន ប៉ុន្តែបណ្ឌិត រមែងកម្ចាត់បង់នូវមន្ទិល គឺ ការខ្វល់ខ្វាយចំពោះរឿងរ៉ាវទាំងនោះបានដោយបញ្ញាដ៏ប្រពៃ ព្រោះបានសំឡឹងចំចំណុចសំខាន់នៃរឿងរ៉ាវទាំងនោះថា រឿងរ៉ាវទាំងនោះជារបស់ប្លម ជារបស់មិនមានពិតដោយបរមត្ថ គ្រាន់តែជាការឆ្នៃប្រឌិតឡើងអាស្រ័យមានចិត្តកើតឡើងប៉ុណ្ណោះ ។ ដូច្នោះ ចិត្តដែលដឹងរឿងរ៉ាវទាំងនោះ មិនមែនជារឿង ត្រឹមតែជាចិត្ត ហើយក៏មិនមែនជាមនុស្សសត្វណា ៗ ដែរ ។

សូមឲ្យការសិក្សាព្រះធម៌របស់ពុទ្ធបរិស័ទ ប្រកបដោយស្មារតីខ្ពស់ ដើម្បីកម្ចាត់នូវការវង្វេងទៅតាមអារម្មណ៍ក្នុងលោក កំណត់ក្នុងចិត្តថា អ្វីដែលកើត ដែលកំពុងប្រព្រឹត្តទៅ និងការបែកធ្លាយ ក្នុងសង្សារវដ្ត សូម្បីក្នុងអតីតដែលរាប់ចំនួនមិនបាន និងតទៅខាងមុខទៀត ត្រឹមតែជាធម៌ប៉ុណ្ណោះ ។

---

# ពាក្យឧទ្ទិស

សូមចំណែកបុណ្យ ដែលកើតឡើងពីសេចក្តីព្យាយាមប្រែរៀបរៀងអដ្ឋកថាទាំងភាសាបាលី និងភាសាខ្មែរនេះ ចូរបានដល់ បុព្វការីជន មានមាតា.បិតារបស់ខ្ញុំ ញាតិទាំងឡាយ ព្រមទាំងសព្វសត្វទាំងអស់ សូមលោកទាំង-ឡាយជួបប្រទះតែសេចក្តីសុខគ្រប់ ៗ កាល ។

---

ហាយ ចំរើន

# មហាសុបិនជាតកំ

( ៧៧ ) ឧសភា រុក្ខា គាវិយោ គវា ច
អស្សោ កំសោ សិគាលី ច កុម្ភោ
បោក្ខរណី ច អបាកចន្ទនំ
លាវូនិ សីទន្តិ សិលា ប្លវន្តិ
មណ្ឌូកិយោ កណ្ហសប្បេ គិលន្តិ
កាកំ សុវណ្ណា បរិវារយន្តិ
តសា វកា ឯឡកានំ ភយា ហិ
វិប្បរិយាយោ វត្តតិ នយិធមត្ថីតិ ។

( មហាសុបិនជាតកំ សត្តមំ )



# មហាសុបិនជាតក

( ៧៧ ) ( ព្រះរាជាទ្រង់ត្រាស់ថា មហាសុបិន ១៦ គឺ ) ៖

គោឡើងកទាំងឡាយ ១ , ឈើទាំងឡាយ ១ , មេគោទាំងឡាយ ១ , គោឈ្មោលទាំងឡាយ ១ , សេះ ១ , ភាជន៍ ( មាស ) ១ , មេចចក ១ , ក្អម ១ , ស្រះបោក្ខរណី ១ , បាយឆៅ ១ , ខ្លឹមចន្ទន៍ ១ , ផ្លែឃ្លោកទាំងឡាយលិច ១ , ថ្មទាំងឡាយអណ្តែត ១ , មេកង្កែបទាំងឡាយខាំពស់វែកទាំងឡាយ ១ , រាជហង្សទាំងឡាយចោមរោមក្អែក ១ , ខ្លាដំបងទាំងឡាយ ( រត់ទៅ ) ព្រោះភ្ញាក់ផ្អើល ដោយសេចក្តីខ្លាចអំពីពពែទាំងឡាយ ១ ។ បរិយាយចំឡែកប្រព្រឹត្តទៅ ន័យទាំងឡាយមានក្នុងសុបិនទាំងនេះ ។

( ចប់មហាសុបិនជាតក ទី ៧ )

ស្រង់ពីព្រះត្រៃបិដក ខុទ្ទកនិកាយ ជាតក សត្តមភាគ លេខ ៥៨

## មហាសុបិនជាតកដ្ឋកថា

លាវូនិ សីទន្តីតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ សោឡស មហាសុបិនោ អារព្ភ កថេសិ ។

ឯកទិវសំ កិរ កោសលមហារាជា រត្តឹ និទ្ទូបគតោ បច្ឆិមយាមេ សោឡស មហាសុបិនេ ទិស្វា ភីតតសិតោ មរណភយតជ្ជិតោ សយនបិដ្ឋេ និសិន្នកោវ រត្តឹ វីតិនាមេសិ ។ អថ នំ បភាតាយ រត្តិយា ព្រាហ្មណបុរោហិតា ឧបសង្កមិត្វា សុខំ សយិត្ថ មហារាជាតិ បុច្ឆិំសុ ។



## អដ្ឋកថា មហាសុបិនជាតក

ព្រះបរមសស្តា កាលប្រថាប់នៅព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធមហាសុបិន ១៦ ប្រការ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា លាវូនិ សីទន្តិ ដូច្នេះ ។

ដូចបានស្តាប់មក ថ្ងៃមួយព្រះបាទកោសលមហារាជ ស្តេចចូលកាន់និទ្រា ក្នុងរាត្រីកាល ក្នុងបច្ឆិមយាម ទតព្រះនេតឃើញព្រះសុបិននិមិត្តដ៏ចំឡែកអស្ចារ្យ ១៦ ប្រការ ទ្រង់តក់ស្លុតព្រះទ័យ តើនពីព្រះបន្ទំ ទ្រង់ព្រះតម្រិះថា យើងឃើញសុបិននិមិត្តទាំងនេះ តើនឹងមានអ្វីកើតឡើងដល់យើងខ្លះហ្ន៎! ព្រះអង្គមានសេចក្តីតក់ស្លុតរន្ធត់ក្រៃលែងទ្រង់ប្រថាប់លើព្រះទែននៅកន្លែងសេយ្យាសន៍នោះឯង រហូតអស់រាត្រីកាល ។

លុះព្រឹកឡើង ពួកព្រាហ្មណ៍បុរោហិតចូលគាល់ ក្រាបទូលសួរថា បពិត្រមហារាជ ព្រះអង្គទ្រង់ផ្ទំជាសុខឬ ? ព្រះរាជា

កុតោ មេ អាចរិយា សុខំ អជ្ជាហំ បច្ចូសសមយេ សោឡស មហាសុបិនោ បស្សឹ សោម្ហិ តេសំ ទិដ្ឋកាលតោ បដ្ឋាយ ភយប្បត្តោតិ វទេថ មហារាជ សុត្វា ជានិស្សាមាតិ វុត្តេ ព្រាហ្មណានំ ទិដ្ឋសុបិនេ កថេត្វា កិន្នុ ខោ ឥមេសំ ទិដ្ឋការណា ភវិស្សទីតិ អាហ ។ ព្រាហ្មណា ហត្ថេ វិធុនឹសុ ។ កស្មា ហត្ថេ វិធុនថាតិ ច វុត្តេ កក្ខឡា- មហារាជ សុបិនាតិ ។ កា តេសំ និប្ផត្តិ ភវិស្សតីតិ ។



ឆ្លើយថា លោកអាចារ្យទាំងឡាយ យើងនឹងមានសេចក្តីសុខបាន យ៉ាងណា កាលពីយប់មិញវេលាជិតភ្លឺ យើងឃើញសុបិននិមិត្ត ១៦ ប្រការ តាំងពីឃើញសុបិននិមិត្តទាំងនោះហើយ យើងដល់នូវ សេចក្តីភ័យខ្លាចយ៉ាងខ្លាំង កាលដែលពួកបុរោហិតក្រាបទូលថា បពិត្រមហារាជទ្រង់ព្រះមេត្តាប្រោសសូមព្រះអង្គត្រាស់រឿងនោះ ចុះ ពួកខ្ញុំព្រះអង្គបានស្តាប់ហើយ នឹងទស្សន៍ទាយថ្វាយបាន ទើប ត្រាស់រឿងព្រះសុបិន ដែលទ្រង់ឃើញហើយ ឲ្យពួកព្រាហ្មណ៍ ស្តាប់ ហើយត្រាស់ថា ព្រោះហេតុឃើញសុបិនទាំងនេះនឹងមានអ្វី កើតឡើងដល់យើងខ្លះ ? ពួកព្រាហ្មណ៍នាំគ្នារាប់ម្រាមដៃ ។ កាល បានត្រូវសួរថា ព្រោះហេតុអ្វី ពួកអ្នកទើបនាំគ្នារាប់ម្រាមដៃ ? ពួកព្រាហ្មណ៍បានក្រាបទូលថា បពិត្រមហារាជ ព្រះសុបិនទាំង- ឡាយនឹងមានអន្តរាយ ព្រះរាជាត្រាស់សួរថា ព្រះសុបិនទាំងនោះ នឹងមានផលដោយប្រការណា ? ពួកព្រាហ្មណ៍នាំគ្នាក្រាបទូលថា

រជ្ជន្តរាយោ រោគន្តរាយោ ជីវិតន្តរាយោ ចាតិ ឥមេសំ តិណ្ណំ អន្តរាយានំ អញ្ញតរោតិ ។

សប្បដិកម្មា អប្បដិកម្មាតិ ។ កាមំ ឯតេ សុបិនា អតិផរុសត្តា អប្បដិកម្មា មយម្បន តេ សប្បដិកម្មេ ករិស្សាម ឯតេ បដិក្កមាបេតុំ អសកោន្តានំ អម្ហាកំ សិក្ខិតភាវោ នាម ករិស្សតីតិ ។ កឹ បន កត្វា អាចរិយា បដិក្កមាបេស្សថាតិ ។ សព្វចតុក្កេន បញ្ញំ យជិស្សាម មហារាជាតិ ។ រាជា ភិតតសិតោ តេនហិ អាចរិយា មម ជីវិតំ តុម្ហាកំ ហត្ថេ



នឹងអន្តរាយ ៣ យ៉ាងទាំងនេះ គឺ អន្តរាយដល់រាជសម្បត្តិ ១ អន្តរាយ គឺ រោគបៀតបៀន ១ អន្តរាយដល់ព្រះជន្ម ១ ឯណានីមួយ ។

ព្រះរាជាសួរថា បា នឹងជួយដោះស្រាយបានឬដោះស្រាយមិនបាន ព្រាហ្មណ៍ទាំងឡាយក្រាបទូលថា បពិត្រមហារាជ ព្រះ-សុបិនទាំងនេះ អស់ផ្លូវដោះស្រាយដោយពិត ព្រោះជាអន្តរាយដ៏ធំ តែពួកខ្ញុំព្រះអង្គទាំងឡាយ នឹងធ្វើឲ្យល្មមកែខៃបាន កាលបើពួកខ្ញុំព្រះអង្គមិនអាចដើម្បីនឹងកែខៃព្រះសុបិនទាំងនេះបានហើយ នឹងឈ្មោះថា ភាពជាអ្នកសម្រេចការសិក្សាបានប្រយោជន៍អ្វី ? ព្រះរាជាត្រាស់សួរថា លោកអាចារ្យទាំងឡាយ នឹងធ្វើយ៉ាងណាឲ្យអន្តរាយនោះវិនាសបាន ពួកព្រាហ្មណ៍នាំគ្នាទូលថា បពិត្រមហារាជ ពួកខ្ញុំព្រះអង្គត្រូវបូជាយញ្ញដោយវត្ថុមួយមុខ៤ៗ គ្រប់យ៉ាង ព្រះអង្គ ព្រះរាជាទ្រង់ធូរព្រះទ័យ ត្រាស់ថា លោកអាចារ្យ

ហោតុ ខិប្បំ មេ សោត្ថឹ ករោថាតិ អាហ ។ ព្រាហ្មណា ពហុធនំ លភិស្សាម ពហុខជ្ជភោជនំ អាហារបស្សាមាតិ ហដ្ឋតុដ្ឋា មា ចិន្តយិត្ថ មហារាជាតិ រាជានំ សមស្សាសេត្វា រាជនិវេសនា និក្ខមិត្វា ពហិនគរេ យញ្ញាវាដំ កត្វា ពហូ ចតុប្បទគណេ ថូនប្បណីតេ កត្វា បក្ខិគណេ សមាហរិត្វា

ឥទញ្ចិទញ្ច លទ្ធុំ វដ្ដតីតិ បុនប្បុនំ សញ្ចរន្តិ ។

អថ ខោ មល្លិកា ទេវី តំ ការណំ ញត្វា រាជានំ ឧបសង្កមិត្វា បុច្ឆិ កឹ នុខោ មហារាជ ព្រាហ្មណា បុនប្បុនំ សញ្ចរន្តីតិ ។ សុខិតា ត្វំ ភទ្ទេ អម្ហាកំ កណ្ណមូលេ អាសីវិសំ សញ្ចរន្តំ ន ជានាសីតិ ។ កឹ ឯតំ មហារាជាតិ ។



ទាំងឡាយបើដូច្នោះយើងសូមប្រគល់ជីវិតក្នុងដៃរបស់ពួកលោកចុះ ពួកលោកប្រញាប់ធ្វើពិធីរំដោះគ្រោះដល់យើងឲ្យរហ័ស ៗ ចុះ ពួកព្រាហ្មណ៍នាំគ្នាត្រេកអររីករាយ ថា ពួកយើងត្រូវបានទ្រព្យសម្បត្តិច្រើន នឹងបានរបស់ទំពាស៊ីច្រើន ៗ ហើយក្រាបទូលដល់ ព្រះរាជាថា បពិត្រមហារាជ សូមទ្រង់កុំវិតក្កឡើយព្រះអង្គហើយ នាំគ្នាចេញចាកពីរាជនិវេសន៍ ចាត់ចែងធ្វើពិធីបូជាយ័ញ្ញនៅទីក្រៅនគរ ចាប់ហ្វូងសត្វជើង ៤ ជាច្រើនចងទុកនឹងទីបង្គោលយ័ញ្ញ រួមទាំងហ្វូងសត្វបក្សីទុកស្រេចហើយ នាំគ្នាដើរទៅដើរមកពោលថា យើងគួរនឹងបានវត្ថុនេះ ៗ ។

គ្រានោះ ព្រះនាងមល្លិកាទេវីទ្រង់ជ្រាបហេតុនោះ ក៏ចូលគាល់ព្រះរាជាក្រាបទូលសួរថា បពិត្រមហារាជ ពួកព្រាហ្មណ៍នាំគ្នាដើរទៅដើរមក តើមានរឿងអ្វីព្រះអង្គ ? ព្រះរាជាត្រាស់ថា ណែ៎នាងដ៏ចម្រើន នាងរវល់តែសុខសប្បាយ ទើបមិនដឹងថាអសិរពិសសញ្ចរនៅជិត ៗ ត្រចៀករបស់យើង ។ ព្រះនាងទូល

មយា ឯវរូបា ទុស្សុបិនា ទិដ្ឋា ព្រាហ្មណា តិណ្ណំ អន្តរាយានំ អញ្ញតរោ បញ្ញាយតីតិ វត្វា តេសំ បដិឃាតាយ យញ្ញំ យជិស្សាមាតិ វត្វា បុនប្បុនំ សញ្ចរន្តីតិ ។ កឹ បន តេ មហារាជ សទេវកេ លោកេ អគ្គព្រាហ្មណោ សុបិនានំ បដិកម្មំ បុច្ឆិតោតិ ។ កតរោ បន សោ ភទ្ទេ សទេវកេ លោកេ អគ្គ-ព្រាហ្មណោតិ ។ សទេវកេ លោកេ អគ្គបុគ្គលំ សព្វញ្ញុំ វិសុទ្ធំ និក្កិលេសំ តថាគតំ គោតមំ មហាព្រាហ្មណំ ន ជានាសិ សោ ហិ ភគវា សុបិនន្តរំ ជានេយ្យ



សួរថា បពិត្រមហារាជ តើរឿងនោះជាយ៉ាងណា ? ព្រះរាជាប្រាប់ថា យើងយល់សប្តិ៍អាក្រក់ណាស់ ពួកព្រាហ្មណ៍នាំគ្នាទស្សន៍-ទាយថា អន្តរាយក្នុង ៣ យ៉ាង ណាមួយក៏នឹងប្រាកដ ដើម្បីកម្ចាត់អន្តរាយទាំងនោះត្រូវបូជាយ័ញ្ញ ទើបត្រូវដើរទៅដើរមកញយៗ ។ ព្រះនាងមល្លិកា ក្រាបទូលសួរថា បពិត្រមហារាជ ក៏អ្នកដែលជាកំពូលលើព្រាហ្មណ៍ក្នុងលោក ព្រមទាំងទេវលោក ព្រះអង្គបានទូលសួរដល់ការដោះស្រាយព្រះសុបិន ហើយឬនៅ ? ព្រះរាជាទ្រង់សួរថា នាងដ៏ចម្រើន លោកដែលជាកំពូលលើព្រាហ្មណ៍ក្នុងលោក ព្រមទាំងទេវលោកនោះ ជានរណាដែរ ? ព្រះនាងក្រាបទូលថា ព្រះពរព្រះអង្គ ទ្រង់មិនជ្រាបទេឬ មហាព្រាហ្មណ៍គោតមដែលជាតថាគត អស់កិលេស បរិសុទ្ធិ៍ហើយ ជាសព្វញ្ញូ ជាបុគ្គលដ៏ប្រសើរបំផុតក្នុងលោក ព្រមទាំងទេវលោក ព្រះមានព្រះភាគព្រះអង្គនោះ គង់ទ្រង់ជ្រាបហេតុក្នុងសុបិនយ៉ាងពិត សូមព្រះអង្គ

គច្ឆ ត្វំ បុច្ឆ តំ មហារាជាតិ ។ សាធុ ទេវីតិ រាជា វិហារំ គន្ត្វា សត្ថារំ វន្ទិត្វា និសីទិ ។

សត្ថា មធុរស្សរំ និច្ឆារេត្វា កិន្នុ ខោ មហារាជ អតិបគេវ អាគតោសីតិ ។ អហំ ភន្តេ បច្ចូសសមយេ សោឡស មហាសុបិនេ ទិស្វា ភីតោ ព្រាហ្មណានំ អារោចេសឹ ព្រាហ្មណា កក្ខឡា មហារាជ សុបិនា ឯតេសំ បដិឃាតនត្ថាយ សព្វចតុកម្មេ យញ្ញំ យជិស្សាមាតិ យញ្ញំ សជ្ជន្តិ ពហូ បាណា មរណភយតជ្ជិតា តុម្ហេ សទេវកេ លោកេ អគ្គបុគ្គលា អតីតានាគតបច្ចុប្បន្នំ ឧបាទាយ នត្ថិ



ស្តេចព្រះរាជដំណើរទៅ ក្រាបទូលសួរចុះ ។ ព្រះរាជាត្រាស់ថា ល្អហើយ ទេវី ហើយស្តេចយាងទៅកាន់ព្រះវិហារ ថ្វាយបង្គំព្រះបាទព្រះបរមសាស្តា ហើយប្រថាប់កន្លែងដ៏សមគួរមួយ ព្រះ-សាស្តាថ្លែងព្រះសូរសៀងដ៏ពីរោះ ត្រាស់សួរថា មហាបពិត្រ ហេតុយ៉ាងណា ទើបទ្រង់យាងមកដូចមានរាជកិច្ចយ៉ាងប្រញាប់ ។ ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នៅពេលជិតភ្លឺ ខ្ញុំព្រះអង្គបានឃើញមហាសុបិន ១៦ ប្រការ គួរឲ្យភ័យខ្លាច ហើយបានប្រាប់រឿងទាំងនោះដល់ពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ទស្សន៍-ទាយថា បពិត្រមហារាជ ព្រះសុបិននេះអាក្រក់ណាស់ព្រះអង្គ ដើម្បីរម្ងាប់សុបិនទាំងនោះ ត្រូវបូជាយ័ញ្ញដោយយ័ញ្ញវត្ថុមួយមុខ ៤ ៗ គ្រប់មុខ ហើយនាំគ្នាត្រៀមបូជាយ័ញ្ញ ហ្វូងសត្វជាច្រើនត្រូវគម្រាមកំហែងដោយមរណភ័យ បពិត្រព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គជាបុគ្គលដ៏កំពូលលើសលោក ទាំងទេវលោក ញ្រ្យ-

សោ ញេយ្យធម្មោ យោ វោ ញាណមុខេ អាបាថំ នាគច្ឆតិ ឯតេសំ មេ សុបិនានំ និប្ផត្តឹ កថេថ ភគវាតិ ។ ឯវមេវ មហារាជ សទេវកេ លោកេ ឋបេត្វា មំ អញ្ញោ ឯតេសំ សុបិនានំ អន្តរំ វា និប្ផត្តឹ វា ជានិតុំ សមត្ថោ នាម នត្ថិ អហំ តេ កថេស្សាមិ អបិច ខោ បន ត្វំ ទិដ្ឋនិយាមេនេវ សុបិនេ កថេហីតិ ។ សាធុ ភន្តេតិ រាជា ទិដ្ឋនិយាមេនេវ កថេតុំ អារភិ

ឧសភា រុក្ខា គាវិយោ គវា ច



ធម៌ដែលចូលទៅកំណត់អតីត អនាគត បច្ចុប្បន្ន ដែលមិនមកកាន់គន្លងញាណមុខរបស់ព្រះអង្គនោះ មិនមានឡើយ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់ប្រោស ទស្សន៍ទាយផលនៃសុបិនរបស់ខ្ញុំព្រះអង្គទាំងនោះផងចុះ ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ថ្វាយព្រះពរ ពិតយ៉ាងនោះហើយមហាបពិត្រ ក្នុងលោកទាំងទេវលោក វៀរតថាគតចេញហើយ អ្នកដទៃនឹងបានឈ្មោះថា អាចដឹងហេតុ ឬ ផលរបស់ព្រះសុបិនទាំងនេះ មិនមានឡើយ តថាគតនឹងទស្សន៍ទាយឲ្យមហាបពិត្រ ប៉ុន្តែថា មហាបពិត្រ ចូរត្រាស់ប្រាប់ព្រះសុបិនតាមទំនង ដែលទ្រង់បានឃើញនោះចុះ ។ ព្រះរាជាទ្រង់ទទួលព្រះពុទ្ធតម្រាស់ថា ករុណាព្រះអង្គហើយផ្តើមក្រាបទូលព្រះសុបិនតាមទំនង ដែលទ្រង់បានឃើញសព្វគ្រប់ ដោយទ្រង់ពោលជាមាតិកាទុក ដូច្នេះថា ៖

គោឧសភរាជទាំងឡាយ ១ ដើមឈើទាំងឡាយ ១

អស្សោ កំសោ សិគាលិ ច កុម្ភោ
បោក្ខរណី ច អបាកចន្ទនំ
លាពូនិ សីទន្តិ សិលា ប្លវន្តិ
មណ្ឌុកិយោ កណ្ហសប្បេ គិលន្តិ
កាកំ សុវណ្ណា បរិវារយន្តិ
តសា វកា ឯឡកានំ ភយា ហីតិ

ឥមំ មាតិកំ និក្ខិបិត្វា កថេសិ អហំ ភន្តេ ឯកំ តាវ សុបិនំ ឯវំ អទ្ទសំ ចត្តារោ អញ្ជនវណ្ណា កាឡឧសភា យុជ្ឈិស្សាមាតិ ចតូហិ ទិសាហិ រាជង្គណំ អាគន្ត្វា ឧសភយុទ្ធំ បស្សិស្សាមាតិ មហាជនេ សន្និបតិតេ យុជ្ឈនាការំ ទស្សេត្វា នទិត្វា គជ្ជិត្វា អយុជ្ឈិត្វាវ បដិក្កន្តា ឥមំ បឋមំ សុបិនំ អទស្សំ ឥមស្ស កោ វិបាកោតិ ។

មហារាជ ឥមស្ស វិបាកោ នេវ តវ ន មម កាលេ



មេគោទាំងឡាយ ១ គោទាំងឡាយ ១ សេះ ១ ថាសមាស ១ ឆ្កែចចក ១ ក្អមទឹក ១ ស្រះបោក្ខរណី ១ បាយឆៅ ១ ខ្ទឹមច័ន្ទ ១ ឃ្លោកលិច ១ ថ្មអណ្តែត ១ មេកង្កែបដេញខាំពស់វែក ១ រាជហង្សចោមរោមក្អែក ១ , ខ្លាដំបងខ្លាចពពែ ១ ។

ហើយត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញសុបិនប្រការទី ១ យ៉ាងនេះមុនថា គោឧសភៈ មានពណ៌ដូចផ្កាអញ្ចាន់ ៤ ក្បាល គិតថានឹងជល់គ្នា នាំគ្នារត់មកកាន់កណ្តាលទីព្រះលានហ្លួង ពីទិសទាំងបួន កាលមហាជនប្រជុំគ្នាគិតថា ពួកយើងនឹងមើលគោឧសភៈជល់គ្នា ដែលកំពុងសម្តែងអាការនឹងជល់គ្នា បន្លឺសំឡេងខ្ទរខ្ទារស្រែករោទិ៍អួតដាក់គ្នា ហើយក៏បែកគ្នាទៅវិញ ដោយមិនបានជល់គ្នាទេ ខ្ញុំព្រះអង្គឃើញសុបិននេះជាបឋម អ្វី ជាផលរបស់សុបិននេះ ព្រះអង្គ ?

មហាបពិត្រ ផលរបស់សុបិនប្រការនេះ មិនមានក្នុងរជ្ជកាល

ភវិស្សតិ អនាគតេ បន អធម្មិកានំ កបណរាជូនំ អធម្មិកានំ ច មនុស្សានំ កាលេ លោកោ វិបរិវត្តមានេ កុសលេ ឱស្សក្កេ អកុសលេ ឧស្សន្នេ លោកស្ស បរិហាន-កាលេ ទេវោ ន សម្មា វស្សិស្សតិ មេឃបាទា ច ឆិជ្ជិស្សន្តិ សស្សានិ មិលាយិស្សន្តិ ទុព្ភិក្ខំ ភវិស្សតិ វស្សិតុកាមា វិយ ចតូហិ ទិសា មេឃា ឧដ្ឋហិត្វា ឥត្ថិកាហិ អាតបេ បត្ថដានំ វីហិអាទីនំ តេមនភ-យេន អន្តោ បវេសិតកាលេ បុរិសេសុ កុទ្ទាលបិដក-ហត្ថេសុ អាឡី ពន្ធនត្ថាយ និក្ខន្តេសុ វស្សនការំ ទស្សេត្វា គជ្ជិត្វា វិជ្ជុលតា និច្ឆារេត្វា តេ ឧសភា វិយ



របស់មហាបពិត្រទេ ក្នុងកាលសាសនារបស់តថាគត ក្នុងកាលអនាគត កាលបើលោកប្រព្រឹត្តទៅជិតដល់ចំណុចជិតវិនាស ក្នុងរជ្ជកាលរបស់ព្រះរាជាដែលកំព្រា មិនបានគ្រប់គ្រងរាជដោយធម៌ និងក្នុងកាលរបស់ពពួកមនុស្សមិនតាំងនៅក្នុងធម៌ កាលបើកុសលអន់ថយចុះ អកុសលធម៌ចម្រើនឡើង ក្នុងកាលដែលលោកវិនាស ភ្លៀងក៏មិនមាន និង ជើងមេឃគ្មានពពក សន្ទូងស្រូវស្ងួតហួតហែង ទុព្ភិក្ខភ័យនឹងកើត ពពកទាំងឡាយតាំងឡើងពីទិសទាំង ៤ ដូចជារកកលនឹងភ្លៀង ពពួកស្រី ៗ ប្រញិប-ប្រញាប់កើបស្រូវអង្ករជាដើម ដែលយកចេញហាលថ្ងៃ បញ្ចូលទុកខាងក្នុងម្លប់ ព្រោះខ្លាចទទឹក កាលបើពពួកបុរស ៗ កាន់ចបកាន់បង្គីនាំគ្នាចេញទៅ ដើម្បីទប់ទឹក មេឃមីរអ្លួរអាប់ ផ្គរលាន់គ្រហឹម ផ្លេកបន្ទោរភ្លឹបភ្លែត តែមិនធ្លាក់ភ្លៀងឡើយ ដុំពពកខ្មៅក៏វិនាសបាត់ទៅ ប្រៀបដូចជា គោឧសភៈដែលរកកលនឹងជល់

អយុជ្ឈិត្វា អវស្សិត្វាវ បលាយិស្សន្តិ អយមេតស្ស វិបាកោ តុយ្ហម្បន តប្បច្ចយា កោចិ អន្តរាយោ នត្ថិ អនាគតំ អារព្ភ ទិដ្ឋោ សុបិនោ ឯស ព្រាហ្មណា បន អត្តនោ ជីវិតវុត្តឹ និស្សាយ កថយឹសូតិ ។ ឯវំ សត្ថា សុបិនស្ស និប្ផត្តឹ កថេត្វា អាហ ទុតិយំ កថេហិ មហារាជាតិ ។

ទុតិយាហំ ភន្តេ ឯវំ អទស្សំ ខុទ្ទករុក្ខា ចេវ គច្ឆា ច បឋវី ភិន្ទិត្វា វិទត្ថិមត្តម្បិ រតនមត្តម្បិ អនុគ្គន្ត្វាវ បុប្ផន្តិ ចេវ ផលន្តិ ច អមំ ទុតិយំ អទស្សំ ឥមស្ស កោ វិបាកោតិ ។ មហារាជ ឥមស្សាបិ វិបាកោ លោកស្ស បរិហីនកាលេ មនុស្សានំ បរិត្តា-



គ្នា តែមិនជល់គ្នាដូច្នោះ នេះជាផលរបស់សុបិននោះ តែមិនមានអន្តរាយណាៗ ដល់មហាបពិត្រ ព្រោះរឿងនោះជាបច្ច័យ មហា-បពិត្រឃើញសុបិននេះ ប្រារព្ធអនាគតប៉ុណ្ណោះ ។ ចំណែកពួកព្រាហ្មណ៍ អាស្រ័យការចិញ្ចឹមជីវិតរបស់ខ្លួន ទើបទស្សន៍ទាយដូច្នេះ ។ ព្រះបរមសាស្ដា លុះត្រាស់ប្រាប់ផលនៃសុបិនដោយប្រការដូច្នេះហើយ ត្រាស់ថា ចូរត្រាស់រឿងសុបិនប្រការទី ២ ចុះមហាបពិត្រ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញសុបិនប្រការទី ២ យ៉ាងនេះថា ដើមឈើតូច ៗ និងគុម្ពឫស្សី ដុះចេញពីផែនដីបានត្រឹម ១ ចង្អាមខ្លះ ១ គក់ខ្លះ ត្រឹមតែប៉ុណ្ណោះ ក៏ចេញផ្កា ចេញផ្លែ តាមគ្នាទៅ នេះជាសុបិនប្រការទី ២ ដែលខ្ញុំព្រះអង្គបានឃើញ អ្វីជាផលរបស់សុបិននេះ ព្រះអង្គ ? ។

មហាបពិត្រ ផលសូម្បីរបស់សុបិនប្រការនេះ ក៏នឹងមាន

យុគកាលេ ភវិស្សន្តិ អនាគតស្មឹ ហិ សត្តា តិព្វរាគា ភវិស្សន្តិ អសម្បត្តវយាវ កុមារិយោ បុរិសន្តរំ គន្ត្វា ឧតុនិយោ ចេវ គព្ភិនិយោ ច ហុត្វា បុត្តធីតាហិ វឌ្ឍិស្សន្តិ ខុទ្ទករុក្ខានំ បុប្ផំ វិយ ហិ តាសំ ឧតុនិកាវោ ផលំ វិយ ច បុត្តធីតារោ វឌ្ឍិស្សន្តិ ឥតោនិទានម្បិ តេ ភយំ នត្ថិ តតិយម្បិ កថេហិ មហារាជាតិ ។

មហាគាវិយោ ភន្តេ តទហុជាតានំ វច្ឆកានំ ខីរំ បិវន្តិយោ អទ្ទសំ អយំ តតិយោ សុបិនោ ឥមស្ស កោ វិបាកោតិ ។ ឥមស្សាបិ វិបាកោ អនាគតេយេវ មនុស្សានំ



ក្នុងកាលដែលលោកវិនាស វេលាមនុស្សមានអាយុតិច ព្រោះថា សត្វទាំងឡាយក្នុងអនាគត នឹងមានរាគៈខ្លាំងក្លា កុមារីមានវ័យមិនទាន់គ្រប់ការ ចេះទាក់ទងនឹងបុរសដទៃ ជាស្ត្រីមានរដូវ មានគភ៌ នាំគ្នាចម្រើនដោយបុត្ត និងធីតា ភាពជាកុមារីទាំងនោះ មានរដូវ ប្រៀបដូចដើមឈើតូច ៗ មានផ្កា កុមារីទាំងនោះ ចម្រើនដោយបុត្ត និងធីតាជាហេតុ ក៏ដូចជាដើមឈើតូច ៗ មានផ្លែ ភ័យសូម្បីមាននិមិត្តនេះជាហេតុ មិនមានដល់មហាបពិត្រទេ ចូរត្រាស់រឿងប្រការទី ៣ តទៅទៀតចុះ មហាបពិត្រ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញមេគោធំ ៗ នាំគ្នាបៅដោះរបស់ហ្វូងកូនគោដែលទើបតែកើតក្នុងថ្ងៃនោះ នេះជាសុបិនប្រការទី ៣ របស់ខ្ញុំព្រះអង្គ តើអ្វីជាផលនៃសុបិននោះព្រះអង្គ ?

មហាបពិត្រ សូម្បីផលរបស់សុបិននេះ ក៏នឹងមានតែក្នុង

ជេដ្ឋាបចាយិកកម្មស្ស ទន្ដកាលេ ភវិស្សតិ អនាគតស្មឹ ហិ សត្តា មាតាបិតូសុ វា សស្សុសស្សុរេសុ វា លជ្ជឹ អនុបដ្ឋបេត្វា សមយេ កុដុម្ពំ សំវិទទិត្វា ឃាសច្ឆាទនមត្តម្បិ មហល្លកានំ ទាតុកាមា ទស្សន្តិ អទាតុកាមា ន ទស្សន្តិ អនាថា អសយំវសី ទារកេ អារាធេត្វា ជីវិស្សន្តិ តទហុជាតានំ វច្ឆកានំ ខីរំ បិវន្តិយោ មហាគាវិយោ វិយ ឥតោនិទានម្បិ តេ ភយំ នត្ថិ ចតុត្ថំ កថេហិ មហារាជាតិ ។

ធុរវាហេ ភន្តេ អារោហបរិណាហសម្បន្នេ មហាគោណេ យុគបរម្បរាយ អយោជេត្វា តរុណេ គោទម្មេ



អនាគតដូចគ្នា នឹងមានផលក្នុងវេលាដែលមនុស្សទាំងឡាយនាំគ្នាលះបង់ជេដ្ឋាបចាយិកកម្ម គឺ ភាពជាអ្នកប្រព្រឹត្តគោរព ឱនលំទោនដល់ចាស់ទុំត្រកូលរាមច្បង ព្រោះក្នុងអនាគត ពពួកសត្វមិនបានតាំងនៅក្នុងសេចក្តីកោតក្រែងក្នុងមាតាបិតា ឬ ក្នុងតាយាយ កាលស្វែងរកទ្រព្យបានដោយខ្លួនឯង ហើយប្រាថ្នានឹងឲ្យរបស់ស៊ី របស់ប្រើដល់មនុស្សចាស់ ៗ ក៏ឲ្យ បើមិនប្រាថ្នានឹងឲ្យ ក៏មិនឲ្យ មនុស្សចាស់ ៗ គ្មានទីពឹង ចិញ្ចឹមជីវិតខ្លួនឯងមិនបាន ត្រូវយកចិត្តថ្នើមពួកក្មេង ៗ ដើម្បីចិញ្ចឹមជីវិត ប្រៀបដូចជាមេគោធំ ៗ នាំគ្នាបៅដោះកូនគោដែលកើតក្នុងថ្ងៃនោះ សូម្បីភ័យ មានសុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រ សូមមហាបពិត្រត្រាស់សុបិនប្រការទី ៤ តទៅទៀតចុះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញពពួកជនមិនទឹមគោធំ ៗ ដែលធ្លាប់អូសរទេះ ដែលមានកម្លាំងខ្លាំងក្លាយកទៅ

ធុរេ យោជេន្តេ អទស្សំ តេ ធុរំ វហិតុំ អសក្កោន្តា ឆឌ្ឌេត្វា អដ្ឋំសុ សកដានិ នប្បវត្តឹសុ អយំ មេ ចតុត្ថោ សុបិនោ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ វិបាកោ អនាគតេយេវ អធម្មិករាជូនំ កាលេ ភវិស្សតិ អនាគតស្មឹ ហិ អធម្មិកកបណរាជានោ បណ្ឌិតានំ បវេណិកុសលានំ កម្មនិត្ថរណសមត្ថានំ មហា- មត្តានំ យសំ ន ទស្សន្តិ ធម្មសភាយំ វិនិច្ឆយដ្ឋានេបិ



ទឹមរទេះទេ ត្រឡប់ជាទៅទឹមកូនគោតូច ៗ ដែលមិនទាន់បានហ្វឹកហាត់ កូនគោតូច ៗ ទាំងនោះមិនអាចនាំរទេះទៅបាន ក៏នាំគ្នារលាស់ចេញពីនឹម ហើយឈរនៅស្ងៀម រទេះទាំងឡាយក៏ទៅមុខមិនបាន នេះជាសុបិនប្រការទី ៤ របស់ខ្ញុំព្រះអង្គ អ្វីជាផលរបស់សុបិននេះ ព្រះអង្គ ? ។

មហាបពិត្រ ផលរបស់សុបិនសូម្បីប្រការនេះ ក៏នឹងមានក្នុងរជ្ជសម័យរបស់ព្រះរាជាអ្នកមិនតាំងនៅក្នុងធម៌ ក្នុងអនាគតដូចគ្នា ដោយថា ក្នុងកាលខាងមុខ ព្រះរាជាអ្នកមានបុណ្យតិចមិនតាំងនៅក្នុងធម៌ នឹងមិនព្រះរាជទានយសដល់មហាអាមាត្យដែលជាបណ្ឌិត ឆ្លាតក្នុងបវេណី មានសមត្ថភាពដែលនឹងញុំាងសព្វកិច្ចឲ្យប្រព្រឹត្តទៅបាន ទ្រង់មិនតែងតាំងអាមាត្យជាអ្នកធំ ជា

បណ្ឌិតេ វោហារកុសលេ មហល្លកេ អមច្ចេ ន ឋបេស្សន្តិ តេ រាជកម្មានិ ចេវ យុត្តាយុត្តញ្ច អជានន្តា នេវ តំ យសំ ឧក្ខិបិតុំ សក្ខិស្សន្តិ ន រាជកម្មានិ និត្ថរិតុំ តេ អសក្កោន្តា កម្មធុរំ ឆឌ្ឌេស្សន្តិ មហល្លកាបិ បណ្ឌិតា អមច្ចា យសំ អលភន្តា កិច្ចានិ និត្ថរិតុំ សមត្ថាបិ កឹ អម្ហាកំ ឯតេហិ មយំ ពាហិរកា ជាតា អព្ភន្តរិកា តរុណា ទារកា ជានិស្សន្តីតិ



អ្នកប្រាជ ឆ្លាតក្នុងវោហារទុកក្នុងទីវិនិច្ឆ័យក្ដីក្នុងសាលាក្ដី តែទ្រង់ព្រះរាជទានយសដល់មនុស្សកំលោះ ៗ ផ្សុយគ្នាដូចដែលពោលហើយមកនោះឯង តែងតាំងបុគ្គលទាំងនោះទុកក្នុងតំណែងជាអ្នកវិនិច្ឆ័យក្ដី មនុស្សកំលោះពួកនោះ មិនចេះដឹងទូទៅដល់រាជកិច្ចនិងការដែលគួរ មិនគួរ មិនអាចរក្សាយសនោះទុកបាន ទាំងមិនអាចចាត់ចែងធ្វើរាជកិច្ចឲ្យប្រព្រឹត្តទៅបាន កាលបើមិនអាចចាត់ចែងបាន ក៏នាំគ្នាលះបង់ធុរៈ ការងារចោលចេញ ចំណែកអាមាត្យដែលជាបណ្ឌិត ជាអ្នកធំ កាលមិនបានយស ទាំងនឹងអាចធ្វើកិច្ចការទាំងឡាយឲ្យប្រព្រឹត្តទៅ ក៏នាំគ្នាពោលថា ពួកយើងត្រូវការអ្វីដោយរឿងទាំងឡាយនេះ ពួកយើងក្លាយជាអ្នកចំណែកខាងក្រៅទៅហើយ ពួកក្មេងកំលោះ ទើបគេជាអ្នកចាត់ចែងកិច្ច

ឧប្បន្នានិ កម្មានិ ន វឌ្ឍិស្សន្តិ ឯវំ សព្វថាបិ តេសំ រាជូនំ ហានិយេវ ភវិស្សតិ ធុរំ វហិតុំ អសមត្ថានំ វច្ឆទម្មានំ ធុរេ យោជិតកាលោ វិយ ធុរវាហានញ្ច មហាគោណានំ យុគបរម្បរាយ អយោជិតកាលេ វិយ ភវិស្សតិ ឥតោនិ-ទានម្បិ តេ ភយំ នត្ថិ បញ្ចមំ កថេហិ មហារាជាតិ ។

ភន្តេ ឯកំ ឧភតោមុខំ អស្សំ អទស្សំ តស្ស ទ្វីសុ បស្សេសុ យវសំ ទេន្តិ សោ ទ្វីហិ មុខេហិ ខាទតិ អយំ មេ បញ្ចមោ សុបិនោ ឥមស្ស កោ វិបាកោតិ ។



ការ គេទើបជាអ្នកចេះដឹង ហើយមិនរក្សាការងារដែលកើតឡើង កាលបើដូច្នេះ សេចក្តីវិនាសប៉ុណ្ណោះ នឹងមានដល់ព្រះរាជាទាំងនោះ ដោយប្រការទាំងពួង ប្រៀបដូចកាលដែលពពួកមនុស្សចាប់កូនគោតូច ៗ កំពុងហ្វឹកហាត់មិនទាន់ស្ទាត់ជំនាញក្នុងការអូសរទេះទៅបាន មកទឹម និងកាលដែលមិនយកគោធំ ៗ ដែលធ្លាប់ទឹមរទេះបាន មកទឹមដូច្នោះ ។ សូម្បីភ័យមានសុបិននេះជាហេតុ ក៏រមែងមិនមានដល់មហាបពិត្រ សូមមហាបពិត្រត្រាស់សុបិនប្រការទី ៥ មកទៀតចុះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញសេះ ១ ក្បាល មានមាត់ពីរ ពពួកជននាំគ្នាឲ្យស្មៅដល់មាត់ទាំងពីររបស់សេះនោះ សេះនោះទំពាស៊ីដោយមាត់ទាំងពីរខាង នេះជាសុបិនទី ៥

ឥមស្សាបិ អនាគតេ អធម្មិករាជកាលេយេវ វិបាកោ ភវិស្សតិ អនាគតស្មឹ ហិ អធម្មិកា ពាលរាជានោ អធម្មិកេ លោលមនុស្សេ វិនិច្ឆយេ ឋបេស្សន្តិ តេ បាបបុញ្ញេសុ អនាទរា ពាលា សភាយំ និសីទិត្វា វិនិច្ឆយំ ទេន្តា ឧភិន្នម្បិ អដ្ដបច្ចត្ថិកានំ ហត្ថតោ លញ្ជំ គហេត្វា ខាទិស្សន្តិ អស្សោ វិយ ទ្វីហិ មុខេហិ យាវសំ ខាទតិ ឥតោនិទានម្បិ តេ ភយំ នត្ថិ ឆដ្ឋំ កថេហិ មហារាជាតិ ។



របស់ខ្ញុំព្រះអង្គ អ្វីជាផលរបស់សុបិននេះ ព្រះអង្គ ? ។

មហាបពិត្រ ផលរបស់សុបិននេះ ក៏នឹងមានក្នុងរជ្ជកាលរបស់ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ក្នុងអនាគតកាលដូចគ្នា ព្រោះថា ក្នុងកាលខាងមុខ ពួកព្រះរាជាល្ងង់ខ្លៅ មិនតាំងនៅក្នុងធម៌ ទ្រង់បានតែងតាំងមនុស្សផ្តេសផ្តាស មិនប្រកបដោយធម៌ ទុកក្នុងតំណែងវិនិច្ឆ័យក្តី មនុស្សទាំងនោះជាបុគ្គលពាល មិនអើពើក្នុងបុណ្យបាប អង្គុយក្នុងសាលាជំនុំ ។ កាលធ្វើការកាត់ក្តី ក៏ទទួលសំណូកពីដៃរបស់គូក្តីទាំងសងខាង ប្រៀបដូចជាសេះស៊ីស្មៅដោយមាត់ទាំងពីរខាងដូច្នោះ ភ័យ សូម្បីមានសុបិននេះជាហេតុ ក៏រមែងមិនមានដល់មហាបពិត្រឡើយ សូមត្រាស់ប្រាប់សុបិនទី ៦ បន្តទៀតចុះ ។

ភន្តេ មហាជនោ សតសហស្សគ្ឃនិកំ សុវណ្ណបាតឹ សម្មជ្ជិត្វា ឥធ បស្សាវំ ករោហីតិ ឯកស្ស ជរសិ- គាលស្ស ឧបនាមេសិ តំ តត្ថ បស្សាវំ ករោន្តំ អទ្ទសំ អយំ មេ ឆដ្ឋោ សុបិនោ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ អនាគតេយេវ វិបាកោ ភវិស្សតិ អនាគតស្មឹ ហិ អធម្មិករាជានោ ជាតិសម្បន្នានំ កុលបុត្តានំ អាសង្កាយ យសំ ន ទស្សន្តិ អកុលីនានំយេវ ទស្សន្តិ ឯវំ មហាកុលានិ ទុគ្គតានិ ភវិស្សន្តិ លាមកកុលានិ



បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញមហាជនដុស ខាត់ថាសមាសដែលមានតម្លៃរាប់សែនកហាបណៈ ហើយនាំគ្នា យកទៅឲ្យឆ្កែចចកចាស់មួយក្បាល ដោយពោលថា សូមលោក ជុះនោមដាក់ក្នុងថាសមាសនេះចុះ ឆ្កែចចកចាស់នោះ ក៏ជុះនោម ដាក់ក្នុងថាសមាសនោះ នេះជាសុបិនប្រការទី ៦ របស់ខ្ញុំព្រះអង្គ អ្វីជាផលនៃសុបិនប្រការនេះ ព្រះអង្គ ? ។

មហាបពិត្រ ផលរបស់សុបិននេះ ក៏នឹងមានក្នុងកាល អនាគតដូចគ្នា ព្រោះថា ក្នុងកាលខាងមុខ ពួកព្រះរាជាមិនតាំង នៅក្នុងធម៌ ទ្រង់ស្អប់ខ្ពើមកុលបុត្តអ្នកសំបូរណ៍ដោយជាតិ ហើយ មិនប្រទានយសឲ្យ បែរជាប្រទានឲ្យដល់អ្នកដែលមិនមានត្រកូល ទៅវិញ កាលបើយ៉ាងនេះ ត្រកូលធំ ៗ ក៏ធ្លាក់ខ្លួនលំបាក ឯ

ឥស្សរានិ តេ ច កុលីនបុរិសា ជីវិតុំ អសក្កោន្តា ឥមេ និស្សាយ ជីវិស្សាមាតិ អកុលីនានំ ធីតរោ ទស្សតិ ឥតិ តាសំ កុលធីតានំ អកុលីនេហិ សទ្ធឹ សំវាសោ ជរសិគាលស្ស សុវណ្ណបាតិយំ បស្សាវ-ករណសទិសោ ភវិស្សតិ ឥតោនិទានម្បិ តេ ភយំ នត្ថិ សត្តមំ កថេហិ មហារាជាតិ ។

ភន្តេ ឯកោ បុរិសោ រជ្ជុំ វដ្ដេត្វា បាទមូលេ និក្ខិបតិ តេន និសិន្នបីឋស្ស ហេដ្ឋា សយិតា ឯកា



ត្រកូលដែលថោកទាប នឹងនាំគ្នាជាធំ ។ ក៏កាលបើពួកអ្នកមានត្រកូលទាំងនោះ មិនអាចរស់នៅបានក៏គិតថា យើងត្រូវអាស្រ័យពួកទាំងឡាយនេះ ទើបអាចរស់តទៅទៀតបាន ហើយក៏នាំគ្នាយកកូនស្រីឲ្យដល់អ្នកមិនមានត្រកូល ការរស់នៅរួមគ្នាជាមួយពួកអ្នកមិនមានត្រកូលរបស់កូនស្រីទាំងនោះ ប្រៀបដូចជាថាសមាសត្រូវឆ្កែចចកចាស់ជុះនោមដាក់ដូច្នោះ ភ័យសូម្បីមានសុបិននេះជាហេតុ ក៏រមែងមិនមានដល់មហាបពិត្រ សូមព្រះអង្គត្រាស់ប្រាប់សុបិន ទី ៧ បន្តទៀតចុះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញយ៉ាងនេះ បុរសម្នាក់អង្គុយវេញខ្សែ ហើយចុងម្ខាងបានធ្លាក់ទៅខាងក្រោមជើងម៉ា មានឆ្កែចចកញីស្រេកឃ្លានមួយក្បាលដេកនៅខាងក្រោម

ធាតសិគាលី តស្ស អជានន្តស្សេវ តំ ខាទតិ ឯវាហំ តំ អទ្ទសំ អយំ មេ សត្តមោ សុបិនោ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ អនាគតេយេវ វិបាកោ ភវិស្សតិ អនាគតស្មឹ ហិ ឥត្ថិយោ បុរិសលោលា សុរាលោលា អលង្ការលោលា វិសិខាលោលា អាមិសលោលា ភវិស្សន្តិ ទុស្សីលា ទុរាចារា តា សាមិកេហិ កសិគោរក្ខាទីនិ កម្មានិ



ជើងម៉ាដែលបុរសអង្គុយ បេះតែអង្គៀមខ្សែនោះ បុរសអ្នកវេញខ្សែនោះពុំបានដឹងឡើយ នេះជាសុបិនប្រការទី ៧ របស់ខ្ញុំព្រះអង្គ អ្វីជាផលនៃសុបិនប្រការនេះ ព្រះអង្គ ? ។

មហាបពិត្រ ផលរបស់សុបិនប្រការនេះ ក៏នឹងមានក្នុងអនាគតឯណោះដូចគ្នា ព្រោះថា ក្នុងកាលខាងមុខ ពួកស្ត្រីក៏កើតសេចក្ដីឡេះឡោះ ភ្លើតភ្លើនក្នុងពួកបុរស ចូលចិត្តក្នុងសុរា ចូលចិត្តតែងខ្លួនដើរលេងកំសាន្តតាមថ្នល់ តាមផ្លូវ ឡេះឡោះនឹងអា-មិស ជាស្ត្រីទ្រុស្តសីល មានការប្រព្រឹត្តិអាក្រក់ ពួកនាងនាំគ្នាយក

កត្វា កិច្ចេន កសិវេន សម្ភតំ ធនំ ខាវេហិ សទ្ធឹ សុរំ បិវន្តិយោ មាលាគន្ធវិលេបនំ ធារយមានា អន្តោគេហេ អច្ចាយិកម្បិ កិច្ចំ អនោលោកេត្វា គេហបរិក្ខេបស្ស ឧប-រិភាគេនបិ ឆិទ្ទដ្ឋានេហិបិ ជារេ ឧបធារយមានា ស្វេ វបិតព្វយុត្តកំ វីហិម្បិ កោដ្ដេត្វា យាគុភត្តខជ្ជកាទីនិ សម្បា-ទេត្វា ខាទមានា វិសុម្បិស្សន្តិ ហេដ្ឋាបីឋកេ និបន្នា ឆាតសិគាលី វិយ វដ្ដេត្វា បាទមូលេ និក្ខិត្តវជ្ជំ ឥតោនិ-ទានម្បិ តេ ភយំ នត្ថិ អដ្ឋមំ កថេហីតិ ។

ភន្តេ រាជទ្វារេ ពហូហិ តុច្ឆកុម្ភេហិ បរិវារេត្វា ឋបិតំ ឯកំ មហន្តំ បូរិតកុម្ភំ អទ្ទសំ ចត្តារោបិ វណ្ណា ចតូហិ ទិសាហិ ចតូហិ អនុទិសាហិ ច ឃដេហិ ឧទកំ អាហរិត្វា



ទ្រព្យដែលប្តីរកបានពីការងារ មានកសិកម្ម និងគោរក្ខកម្មជាដើម ដែលសន្សំទុកដោយលំបាកលំបិន យកទៅទិញស្រាផឹកជាមួយប្រុសសាហាយ ទិញផ្កាឈើ របស់ក្រអូប គ្រឿងលាបមកតែងខ្លួន គយគន់រកមើលសាហាយ អំពីខាងលើផ្ទះខ្លះ អំពីទីស្វាត់កំបាំងខ្លះ សូម្បីពូជស្រូវដែលត្រៀមសម្រាប់សាបព្រោះក្នុងថ្ងៃស្អែក ក៏យកទៅបុកដាំបាយ បបរ និងរបស់ទំពាស៊ី មកនាំគ្នាស៊ី ប្រៀបដូចជាមេចចកស្រេកឃ្លាន ដែលដេកនៅក្រោមតាំង ហើយទំពាស៊ីកន្ទុយខ្សែ ដែលបុរសនោះបានវេញទម្លាក់ចុះក្បែរជើងខ្លួន ដូច្នោះៗក័យ សូម្បីមានសុបិននេះជាហេតុ ក៏មិនមានដល់មហា-បពិត្រឡើយ សូមទ្រង់ត្រាស់សុបិនប្រការទី ៨ បន្តទៀតចុះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញពាងទឹកមួយមានទឹកពេញប្រៀបដាក់តាំនៅជិតទ្វាររាំង ហើយមានពាងទទេតូច ៗ ជាច្រើននៅព័ទ្ធជុំវិញ វណ្ណៈទាំងបួន កាន់ផ្ទាំងដាក់ទឹកមកពីទិសទាំងបួន និងទិសតូច ៗ ទាំងឡាយ យកមកចាក់ក្នុងពាង

បូរិតកុម្ភមេវ បូរេន្តិ បូរិតបូរិតំ ឧទកំ ឧត្តរិត្វា បលាយតិ តេបិ តត្ថេវ បុនប្បុនំ ឧទកំ អាសិញ្ចន្តិ តុច្ឆកុម្ភេ បន ឱលោកេន្តាបិ នត្ថិ អយំ មេ អដ្ឋមោ សុបិនោ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ អនាគតេយេវ វិបាកោ ភវិស្សតិ អនាគតស្មឹ ហិ លោកោ បរិហាយិស្សតិ រដ្ឋំ និរោជំ ភវិស្សតិ រាជានោ ទុគ្គតា កបណា ភវិស្សន្តិ យោ ឥស្សរោ ភវិស្សតិ តស្ស ភណ្ឌាគារេ សតសហស្សមត្តា កហាបណា ភវិស្សន្តិ តេ ឯវំ ទុគ្គតា សព្វេ ជនបទេ អត្តនោ វបកម្មំ ការេស្សន្តិ ឧបទ្ទុតា មនុស្សា សកេ កម្មន្តេ ឆឌ្ឌេត្វា រាជូនញ្ញេវ អត្ថាយ បុព្វន្នាបរន្នានិ ច វបន្តា រក្ខន្តា លាយន្តា មទ្ទន្តា



ដែលមានទឹកពេញហើយនោះឯង ទឹកក៏ហៀរហូរចេញទៅ សូម្បីដូច្នោះ គេនៅតែនាំគ្នាដងទឹកយកមកចាក់ដាក់ពាងធំដែលមានទឹកនោះរឿយ ៗ ដោយមិនរវល់ ដោយមិនរវល់មើលដល់ពាងដែលគ្មានទឹកឡើយ នេះជាសុបិនប្រការទី ៨ របស់ខ្ញុំព្រះអង្គ អ្វីជាផលរបស់សុបិននេះ ព្រះអង្គ ? ។

មហាបពិត្រ ផលនៃសុបិននេះ នឹងមានក្នុងអនាគតដូចគ្នា ព្រោះថា ក្នុងកាលខាងមុខលោកនឹងវិនាស ស្រុកនិគមនឹងក្រខ្សត់ អត់ឃ្លាន ព្រះរាជាទាំងឡាយក៏ក្រលំបាក ព្រះរាជាអង្គណាដែលជាធំ មានអំណាច មានទ្រព្យយ៉ាងច្រើនត្រឹមមួយសែនកហាបណៈទុកក្នុងឃ្លាំង ព្រះរាជាទាំងនោះក្រលំបាកយ៉ាងនេះ ក៏កេណ្ឌប្រជារាស្ត្រគ្រប់គ្នាឲ្យធ្វើស្រែចំការយកភោគផលដាក់ឃ្លាំងព្រះរាជទ្រព្យ ។ ប្រជារាស្ត្រនាំគ្នាសាបព្រោះបុព្វណ្ណជាតិ និងអបរណ្ណជាតិជាដើម ថ្វាយដល់ព្រះរាជាទាំងឡាយនោះប៉ុណ្ណោះ នាំគ្នារក្សា

បវេសេន្តា ឧច្ឆុក្ខេត្តានិ ករោន្តា យន្តានិ ករេន្តា វាហេន្តា ផាណិតាទីនិ បចន្តា បុប្ផារាមេ ផលារាមេ ច ករេន្តោ តត្ថ តត្ថ និប្ផន្នានិ បុព្វន្នាទីនិ អាហរិត្វា រញ្ញោ កោដ្ឋាគារំ យេវ បូរេស្សន្តិ អត្តនោ គេហេសុ តុច្ឆកោដ្ឋេ ឱលោកេន្តាបិ ន ភវិស្សន្តិ តុច្ឆកុម្ភេ អនោលោកេត្វា បូរិតកុម្ភបូរណសទិ-សមេវ ភវិស្សតិ ឥតោនិទានម្បី តេ ភយំ នត្ថិ នវមំ កថេហីតិ ។

ភន្តេ ឯកំ បញ្ចវណ្ណប្បទុមសញ្ឆន្នំ គម្ភីរំ សព្វតោតិត្ថំ បោក្ខរណឹ អទ្ទសំ សមន្តតោ ទ្វិបទចតុប្បទា ឱតរិត្វា តត្ថ បានីយំ បិវន្តិ តស្សា មជ្ឈេ គម្ភីរដ្ឋានេ ឧទកំ អាវិលំ



ប្រូត បោក ដឹកជញ្ជូន ស្ងោររំងាស់ទឹកអំពៅជាដើម និងជួយធ្វើចំការផ្កាឈើ និងផ្លែឈើ នាំគ្នាជញ្ជូនបុព្វណ្ណជាតិជាដើមស្រេចហើយ ក្នុងទីនោះ ៗ មកដាក់ទុកក្នុងព្រះរាជឃ្លាំង សូម្បីក្រឡេកមើលឃើញជង្រុកនៃផ្ទះទាំងឡាយរបស់ខ្លួនទទេ ក៏មិនហ៊ានទុកដាក់ឡើយ ប្រៀបដូចជាការបន្ថែមទឹកទៅក្នុងពាងដែលមានទឹកពេញហើយ មិនរវល់មើលពាងទាំងឡាយដែលគ្មានទឹកដូច្នោះ ។ ភ័យ សូម្បីមានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រទេ សូមទ្រង់ត្រាស់ប្រាប់សុបិនទី ៩ បន្តទៀតចុះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញស្រះបោក្ខរណីមួយពោរពេញទៅដោយបទុម ៥ ពណ៌ មានទឹកជ្រៅត្រង់កណ្តាល មានកំពង់សម្រាប់ចុះឡើងជុំវិញ សត្វទ្វេបាទ ចតុប្បាទ តែងនាំគ្នាចុះផឹកទឹកក្នុងស្រះនោះដោយជុំវិញ ។ ប៉ន្តែចំឡែកត្រង់កណ្តាលស្រះដែលមានទឹកជ្រៅ ទៅជាល្អក់ ចំណែកទឹកខាង ៗ ជុំវិញស្រះ

តីរប្បទេសេសុ ទ្វិបទចតុប្បទានំ អក្កមនដ្ឋានេ អច្ឆំ វិប្បសន្នំ អនាវិលំ ឯវាហំ អទ្ទសំ អយំ មេ នវមោ សុបិនោ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ អនាគតេយេវ វិបាកោ ភវិស្សតិ អនាគតស្មឹ ហិ រាជានោ អធម្មិកា ភវិស្សន្តិ ឆន្ទាទិវសេន អគតិគមនំ គច្ឆន្តា រជ្ជំ ការេស្សន្តិ ធម្មេន វិនិច្ឆយំ នាម ន ទស្សន្តិ លញ្ចវិត្តកា ភវិស្សន្តិ ធនលោលា រដ្ឋវាសិកេសុ តេសំ ខន្តិមេត្តានុទ្ទយា នាម ន ភវិស្សន្តិ កក្ខឡា ផរុសា ឧច្ឆុយន្តេ ឧច្ឆុគណ្ឋិកា វិយ មនុស្សេ បីឡេន្តា



ប្រែជាថ្លាល្អ សូម្បីពួកសត្វជាច្រើនចុះផឹកក៏ដោយ ទឹកនៅតែថ្លាដដែល ។ ខ្ញុំព្រះអង្គបានឃើញយ៉ាងនេះ នេះជាសុបិនប្រការទី ៩ របស់ខ្ញុំព្រះអង្គ អ្វីជា ផលរបស់សុបិននេះ ព្រះអង្គ ? ។

ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះនឹងមានក្នុងអនាគតកាលដូចគ្នា ព្រោះថា ក្នុងកាលខាងមុខ ព្រះរាជាទាំងឡាយនឹងមិនតាំងនៅក្នុងធម៌ លុះក្នុងអគតិធម៌ ដោយអំណាចសេចក្តីស្រឡាញ់ជាដើម សោយរាជសម្បត្តិ មិនប្រទានការវិនិច្ឆ័យឲ្យបានត្រឹមត្រូវប្រកបដោយធម៌ មានព្រះហឫទ័យស្វែងរកតែសំណូក ល្មោភក្នុងទ្រព្យសម្បត្តិ ដែលថាគុណធម៌ គឺ សេចក្តីអត់ធន់ សេចក្តីមេត្តា និងសេចក្តីអាណិតអាសូររបស់ព្រះរាជាទាំងនោះ នឹងមិនមានក្នុងប្រជារាស្ត្រទាំងឡាយ ជាអ្នកគិតតែប្រយោជន៍ផ្ទាល់ខ្លួន បៀតបៀនរាស្ត្រ ដូចគេគាបអំពៅដោយគ្រឿងយន្ត តម្រូវយកសួយផ្សេង ៗ ពួកគេ

នានប្បការំ ផលឹ ឧប្បាទេត្វា ធនំ គណ្ហិស្សន្តិ មនុស្សា ពលិបីឡិតា កិញ្ចិ ទាតុំ អសក្កោន្តា គាមនិគមាទយោ ឆឌ្ឌេត្វា បច្ចន្តំ គន្ត្វា វាសំ កប្បេស្សន្តិ មជ្ឈិមជនបទោ វាសំ កប្បេស្សន្តិ មជ្ឈិមជនបទោ សុញ្ញោ ភវិស្សតិ បច្ចន្តោ ឃនវាសោ សេយ្យថាបិ បោក្ខរណិយា វេមជ្ឈេ ឧទកំ អាវិលំ បរិយន្តេ វិប្បសន្នំ ឥតោនិទានម្បិ តេ ភយំ នត្ថិ ទសមំ កថេហីតិ ។

ភន្តេ ឯកិស្សាយេវ កុម្ភិយា បច្ចមានំ ឱទនំ អបាកំ អទ្ធសំ អបាកន្តិ វិចារេត្វា វិភជិត្វា ឋបិតំ វិយ តីហាការេហិ បច្ចមានំ ឯកស្មឹ បស្សេ អតិកិលិន្នោ ហោតិ ឯកស្មឹ ឧត្តណ្ឌុលោ ឯកស្មឹ សុបក្កោ អយំ មេ ទសមោ សុបិនោ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ អនាគតេយេវ វិបាកោ ភវិស្សតិ អនាគតស្មឹ



ត្រូវព្រះរាជាបង្ខឹរឹបអូសយកសួយអាករយ៉ាងច្រើន គេមិនអាចនឹងឲ្យអ្វី ៗ បាន ក៏នាំគ្នាបោលស្រុកនិគមជាដើម ហើយកៀសខ្លួនចេញទៅកាន់ជាយដែន តាំងលំនៅដ្ឋានក្នុងទីនោះណែនណាន់តាន់តាប់ រីឯជនបទស្រុកនិគម ប្រែជាស្ងប់ស្ងាត់សូន្យទទេ ដូចទឹកកណ្ដាលស្រះបោក្ខរណីទៅជាល្អក់ចំណែកទឹកជុំវិញក្បែរមាត់ស្រះទៅជាថ្លា យ៉ាងណា ភ័យ សូម្បីមានសុបិននេះជាហេតុ ក៏មិនមានដល់នហាបពិត្រ សូមទ្រង់ត្រាស់ព្រះសុបិនប្រការទី ១០ នប្តទៀតចុះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញបាយ ដែលមនុស្សដាំក្នុងឆ្នាំងតែមួយ ឆៅក៏មាន ឆ្អិនក៏មាន ជ្រាយក៏មាន នេះជាសុបិនទី ១០ របស់ខ្ញុំព្រះអង្គ អ្វីជាផលរបស់សុបិនប្រការនេះ ព្រះអង្គ ? ។

ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា មហាបពិត្រ នឹងមានក្នុង

ហិ រាជានោ អធម្មិកា ភវិស្សតិ តេសុ អធម្មិកេសុ រាជ-
យុត្តបិ ព្រាហ្មណគហបតិកាបិ នេគមជានបទាបីតិ សមណ-
ព្រាហ្មណេ ឧបាទាយ សព្វេ មនុស្សា អធម្មិកា ភវិស្សន្តិ
តតោ តេសំ អារក្ខទេវតា ពលិប្បដិគ្គាហកទេវតា រុក្ខទេវតា
អាកាសដ្ឋកទេវតា អធម្មិកា ភវិស្សន្តិ ឯវំ ទេវតាបិ
អធម្មិកា ភវិស្សន្តិ អធម្មិករាជូនំ រជ្ជេ វាតា វិសមា ខរា
វាយិស្សន្តិ តេ អាកាសដ្ឋកវិមានានិ កម្បេស្សន្តិ តេសុ
កម្បិតេសុ ទេវតា កុបិតា ទេវំ វស្សតុំ ន ទស្សន្តិ
វស្សមានោបិ សកលរដ្ឋេ ឯកប្បហារេនេវ ន វស្សិស្សតិ
វស្សមានោបិ សព្វត្ថ កសិកម្មស្ស វា វបកម្មស្ស វា
ឧបការោ ហុត្វា ន វស្សិស្សតិ យថា ច រដ្ឋេ ឯវំ



អនាគតកាលដូចគ្នា ព្រោះថា ក្នុងកាលខាងមុខព្រះរាជាទាំង-
ឡាយមិនតាំងនៅក្នុងធម៌ កាលបើព្រះរាជាទាំងនោះមិនតាំងនៅ
ក្នុងធម៌ហើយ អ្នករាជការក្តី ព្រាហ្មណ៍ និងគហបតីក្តី អ្នកនិគម
អ្នកជនបទក្តី រួមមនុស្សទាំងអស់ រាប់តាំងពីសមណៈ និង
ព្រាហ្មណ៍ ក៏មិនតាំងនៅក្នុងធម៌ សូម្បីទេវតាទាំងឡាយក៏មិនតាំង
នៅក្នុងធម៌ ក្នុងរជ្ជកាលនៃអធម្មិករាជទាំងឡាយ ខ្យល់ទាំងឡាយ
ក៏បក់មិនស្មើ បក់ខ្លាំង ៗ ធ្វើឲ្យវិមានក្នុងអាកាសរបស់ទេវតា
ញាប់ញ័រ កាលវិមានទាំងនោះត្រូវខ្យល់បក់ធ្វើឲ្យញាប់ញ័រ ពពួក
ទេវតាក៏នាំគ្នាក្រោធខឹង ហើយក៏មិនបណ្តាលឲ្យភ្លៀងធ្លាក់ តែបើ
ភ្លៀងធ្លាក់ ក៏ធ្លាក់មិនស្មើទូទៅដល់ស្រុកនិគម មិនដូច្នោះ នឹងមិន
ធ្លាក់ ដើម្បីជាឧបការៈដល់ការងារសាបព្រោះក្នុងទីទាំងពួង មិន
ធ្លាក់ទូទៅដល់ជនបទ សូម្បីក្នុងស្រុក សូម្បីក្នុងត្រពាំងមួយ សូម្បី
ក្នុងកូនស្រះមួយ ដូចគ្នានឹងដែនដូច្នោះ កាលធ្លាក់ខាងជើងត្រពាំង

ជនបទេបិ គាមេបិ ឯកតឡាកេបិ ឯកសរេបិ ឯកប្បការេន ន វស្សិស្សតិ តឡាកស្ស ឧបរិភាគេ វស្សន្តោ ហេដ្ឋាភាគេ ន វស្សិស្សតិ ហេដ្ឋា វស្សន្តោ ឧបរិ ន វស្សិស្សតិ ឯកស្មឹ ភាគេ សស្សំ អតិវស្សេន នាសេស្សតិ ឯកស្មឹ អវស្សន្តោ សស្សំ មិលាបេស្សតិ ឯកស្មឹ សម្មា វស្សមានោ សម្បាទេស្សតិ ឯវំ ឯកស្ស រញ្ញោ រជ្ជេ វុត្តសស្សា និប្បការា ភវិស្សន្តិ ឯកកុម្ភិយា ឱទនោ វិយ ឥតោនិទានម្បិ តេ ភយំ នត្ថិ ឯកាទសមំ កថេហីតិ ។

ភន្តេ សតសហស្សគ្ឃនិកំ ចន្ទនសារំ បូតិតក្កេន វិក្កិណន្តេ អទ្ទសំ អយំ មេ ឯកាទសមោ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ អនាគតេយេវ មយ្ហំ សាសនេ បរិហាយន្តេ



ក៏មិនធ្លាក់ខាងត្បូងត្រពាំង បើធ្លាក់ខាងត្បូង ក៏មិនធ្លាក់ខាងជើង ស្រូវមួយផ្នែកក៏ខូច ព្រោះភ្លៀងជោកជាំ កាលភ្លៀងមិនធ្លាក់ក្នុងផ្នែកមួយទៀត ស្រូវក៏ស្វិតស្រពោន កាលភ្លៀងធ្លាក់ល្អក្នុងផ្នែកមួយ ស្រូវក៏សម្បូរណ៍ ស្រូវដែលសាបព្រោះហើយក្នុងសីមារបស់ព្រះរាជាមួយអង្គ នឹងមាន ៣ ផ្នែក ដោយប្រការដូច្នេះ ។ ភ័យសូម្បីមានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រទេ សូមទ្រង់ត្រាស់សុបិនទី ១១ បន្តទៀតចុះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញមនុស្សទាំង-ឡាយយកខ្លឹមចន្ទន៍ដែលមានតម្លៃទាំងសែនកហាបណៈ ដោះដូរជាមួយប្រេងស្អុយ នេះជាសុបិនប្រការទី ១១ របស់ខ្ញុំព្រះអង្គ អ្វីជាផលនៃសុបិនប្រការនេះ ព្រះអង្គ ? ។

មហាបពិត្រ ផលនៃសុបិននេះ ក៏មានក្នុងអនាគតឯណោះ ក្នុងកាលសាសនារបស់តថាគតរោយរាវចុះនោះឯង ព្រោះថាក្នុង

វិបាកោ ភវិស្សតិ អនាគតស្មឹ ហិ បច្ចយលោលា អលជ្ជី ភិក្ខូ ពហូ ភវិស្សន្តិ តេ មយា បច្ចយលោលុប្បំ និម្មថេត្វា កថិតធម្មទេសនំ ចីវរាទិចតុប្បច្ចយហេតុ បរេសំ ទេសេស្សន្តិ បច្ចយេហិ មុច្ចិត្វា និស្សរណបក្ខេ ឋិតា និព្វានាភិមុខំ កត្វា ទេសេតុំ ន សក្ខិស្សន្តិ កេវលំ បទព្យញ្ជនសម្បត្តិញ្ចេវ មធុរសទ្ទញ្ច សុត្វា មហគ្ឃានិ ចីវរាទីនិ ទស្សន្តិ ចេវ ទាបេស្សន្តិ ច អបរេ អន្តរវីថិចតុក្ករាជទ្វារាទីសុ និសីទិត្វា កហាបណឌ្ឍកហាបណបាទមាសករូបាទីនិ និស្សាយ ទេសេស្សន្តិ ឥតិ មយា និព្វានគ្ឃនកំ



កាលខាងមុខ ពួកភិក្ខុអលជ្ជីសំឡឹងដល់បច្ច័យ មានច្រើន ពួកទាំងនោះ នឹងនាំគ្នាសម្តែងធម៌ទេសនា ដែលតថាគតពោលតិះដៀលពីការល្មោភក្នុងបច្ច័យទុកដល់ជនដទៃ ព្រោះហេតុនៃបច្ច័យ ៤ មានចីវរជាដើម នឹងមិនអាចសម្តែងឲ្យផុតពីបច្ច័យទាំងឡាយ ហើយតាំងនៅក្នុងចំណែកនៃធម៌ដែលនាំសត្វឲ្យផុតចាកទុក្ខ មានមុខឆ្ពោះកាន់ព្រះនិព្វាន ។ ជនទាំងឡាយក៏នឹងស្តាប់នូវភាពសម្បូរនៃបទ និងព្យញ្ជនៈ និងសូរសៀងដ៏ពីរោះតែម្យ៉ាងប៉ុណ្ណោះ ហើយក៏ថ្វាយបច្ច័យទាំងឡាយ និងញ៉ាំងជនទាំងឡាយដទៃឲ្យថ្វាយនូវបច្ច័យទាំងឡាយ មានចីវរជាដើម ដែលមានតម្លៃច្រើន ។ ភិក្ខុទាំងឡាយពួកដទៃទៀត នាំគ្នាអង្គុយក្នុងផ្លូវផ្សេង ៗ មានផ្លូវបែកជាបួន និងតាមខ្លោងទ្វាររាជវាំងជាដើម ហើយសម្តែងធម៌ដូរយករូបិយៈ សូម្បីកន្លះកហាបណៈ មួយបាទ មួយមាសក ជាដើម ដោយប្រការដូច្នេះ ក៏យកធម៌ដែលតថាគតសម្តែងទុក មានតម្លៃ

កត្វា ទេសិតធម្មំ ចតុប្បច្ចយត្ថាយ ចេវ កហាបណាឌ្ឍ-កហាបណាទីនំ អត្ថាយ ច វិកិណ្ណិត្វា ទេសេត្វា សតសហ-ស្សគ្ឃនិកំ ចន្ទនសារំ បូតិតក្កេន វិក្កិណន្តា វិយ ភវិស្សន្តិ ឥតោនិទានម្បិ តេ ភយំ នត្ថិ ទ្វាទសមំ កថេហីតិ ។

ភន្តេ តុច្ឆលាពូនិ ឧទកេ សីទន្តានិ អទ្ទសំ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ អនាគតេ អធម្មិករាជកាលេ លោកេ វិបរិវត្តន្តេយេវ វិបាកោ ភវិស្សតិ តទា ហិ រាជានោ ជាតិសម្បន្នានំ កុលបុត្តានំ យសំ ន ទស្សន្តិ អកុលីនានំ-



គួរដល់ព្រះនិព្វាន ទៅសម្តែងដូរជាមួយបច្ច័យ ៤ និងរូបិយៈមានមួយកហាបណៈ កន្លះកហាបណៈជាដើម ប្រៀបដូចពពួកមនុស្សយកខ្លឹមច័ន្ទដែលមានតម្លៃទាំងសែន ទៅប្តូរយកប្រេងស្អុយដូច្នោះ ភ័យ សូម្បីមានសុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រទេ សូមទ្រង់ត្រាស់សុបិនទី ១២ បន្តទៀតចុះ មហាបពិត្រ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញផ្លែឃ្លោកដែលគេយកបណ្តូលចេញអស់ហើយ លិចទឹក អ្វីជាផលនៃសុបិននេះព្រះអង្គ ? ។

មហាបពិត្រ ផលនៃសុបិននេះ ក៏នឹងមានក្នុងអនាគត កាលលោកប្រព្រឹត្តទៅជិតនឹងវិនាស ក្នុងរជ្ជកាលរបស់ព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ព្រោះថា ក្នុងគ្រានោះ ព្រះរាជាទាំងឡាយនឹងមិនព្រះរាជទានយសដល់កុលបុត្តអ្នកសម្បូរណ៍ដោយជាតិ តែរជាព្រះរាជទានដល់អ្នកគ្មានត្រកូលទៅវិញ ពួកនោះនឹងជាធំ រីឯ

យេវ ទស្សន្តិ តេ ឥស្សរា ភវិស្សន្តិ ឥតរេ ទលិទ្ទា រាជសម្មុខេបិ រាជទ្វារេបិ អមច្ចសម្មុខេបិ វិនិច្ឆយដ្ឋានេបិ តុច្ឆលាពុសទិសានំ អកុលីនានញ្ញេវ កថា ឱសីទិត្វា ឋិតា វិយ និច្ចលា សុប្បតិដ្ឋិតា ភវិស្សន្តិ សង្ឃសន្និបាតេបិ សង្ឃកម្មគណកម្មដ្ឋានេសុ ចេវ បត្តចីវរបរិវេណាទិវិនិច្ឆយដ្ឋានេសុ ច ទុស្សីលានំ បាបបុគ្គលានំយេវ កថា និយ្យានិកា ភវិស្សន្តិ ន លជ្ជីនំ ភិក្ខូនំ ឯវំ សព្វថាបិ តុច្ឆលាពុសីទនកាលោ វិយ ភវិស្សតិ ឥតោនិទានម្បិ តេ ភយំ នត្ថិ តេរសមំ កថេហីតិ ។



អ្នកមានត្រកូលក៏ទៅជាក្រលំបាក ។ ពាក្យសំដីពួកអ្នកគ្មានត្រកូល ដូចជាសំបកឃ្លោក ហាក់ដូចជាឫសឈើដុះចាក់ស្រេះក្នុងទីចំពោះព្រះភក្ត្រព្រះរាជាក្តី ទីទ្វារព្រះរាជវាំងក្តី ទីប្រជុំអមាត្យក្តី ទីសាលាជំនុំក្តី ក៏គឺជាពាក្យប្រចុបប្រចែងមិនបានការ គ្មានមូលដ្ឋានច្បាស់លាស់ សូម្បីក្នុងសង្ឃសន្និបាត ក្នុងកិច្ចកម្មដែលសង្ឃគប្បីធ្វើ និងគណៈដែលគប្បីធ្វើក្តី ទាំងក្នុងកន្លែងដែលមានអធិករណ៍ ទាក់ទងនឹងបាត្រ ចីវរ និងបរិវេណជាដើមក្តី ពាក្យសំដីរបស់មនុស្សអាក្រក់ទ្រុស្តសីលប៉ុណ្ណោះ ជាពាក្យដែលគេយល់ថា នាំសត្វចេញចាកទុក្ខបាន មិនមែនជាពាក្យសំដីរបស់ភិក្ខុដែលជាលជ្ជីទេ កាលបើដូច្នេះ ក៏ដូចជាកាលដែលលិចចុះនៃសំបកឃ្លោក សូម្បីដោយប្រការទាំងពួង ។ ភ័យ សូម្បីមានសុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រ សូមទ្រង់ត្រាស់សុបិនទី ១៣ បន្តទៀតចុះ ។

ភន្តេ មហន្តា កូដាគារប្បមាណា ឃនសិលានាវា វិយ ឧទកេ ប្លវមានា អទ្ទសំ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ តាទិសោយេវ កាលេ វិបាកោ ភវិស្សតិ តទា ហិ អធម្មិករាជានោ អកុលីនានំ យសំ ទស្សន្តិ តេ ឥស្សរា ភវិស្សន្តិ កុលីនា ទុគ្គតា តេសុ ន កេចិ គារវំ ករិស្សន្តិ ឥតរេសុយេវ ករិស្សន្តិ រាជសម្មុខេ វា អមច្ចសម្មុខេ វា វិនិច្ឆយដ្ឋានេ វា វិនិច្ឆយដ្ឋានេ វា វិនិច្ឆយកុសលានំ ឃនសិលាសទិសានំ កុលបុត្តានំ កថា ន ឱគាហិត្វា បតិដ្ឋហិស្សតិ តេសុ កថេន្តេសុ កឹ ឥមេ



បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញដុំថ្មតាន់ប៉ុនប្រាសាទ អណ្តែតលើទឹកដូចជាទូក អ្វីជាផលនៃសុបិននេះ ព្រះ-អង្គ ? ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា បពិត្រមហារាជ ក្នុងកាលអនាគត ព្រះរាជាមិនតាំងនៅក្នុងធម៌ ចូលចិត្តតែងតាំងមនុស្សថោកទាបគ្មានត្រកូល ឲ្យជាធំ ឯមនុស្សអ្នកមានពូជពង្សវង្សត្រកូលត្រឹមត្រូវ ក៏ទៅជាដុនដាបតោកយ៉ាក នរណា ៗ ក៏មិនធ្វើសេចក្តីគោរពកោតក្រែងដល់អ្នកមានត្រកូលនោះ បែរជាគោរពចំពោះអ្នកដែលគ្មានត្រកូល ជាអ្នកធំទៅវិញ ពាក្យសំដីរបស់កុលបុត្តអ្នកឆ្លាតក្នុងការវិនិច្ឆ័យ នឹងត្រឹមត្រូវ ដូចជាដុំថ្មតាន់ នឹងមិនលិចចុះក្នុងទឹកឡើយ ។ ស្ថិតនៅទីចំពោះព្រះភក្ត្ររបស់ព្រះ-រាជា ឬក្នុងទីជំនុំអមាត្យ ឬក្នុងសាលាក្តី កាលបើពួកនោះកំពុងពោល ពួកដទៃក៏ចំអកឡកឡឺយថា ពួកនេះនិយាយអ្វី សូម្បីក្នុង

កថេន្តីតិ ឥតរេ បរិហាសមេវ ករិស្សន្តិ ភិក្ខុសន្និបាតេបិ វុត្តប្បការេសុ ឋានេសុ នេវ បេសលេ ភិក្ខូ គរុកាតព្វេ មញ្ញិស្សន្តិ នាបិ តេសំ កថា បរិយោគាហិត្វា បតិដ្ឋហិស្សតិ សិលានំ ប្លវនកាលោ វិយ ភវិស្សតិ ឥតោនិទានម្បិតេ ភយំ នត្ថិ ចុទ្ទសមំ កថេហីតិ ។

ភន្តេ ខុទ្ទកមណ្ឌុកបុប្ផប្បមាណា មណ្ឌូកិយោ មហន្ត-មហន្តេ កណ្ហសប្បេ វេគេន អនុពន្ធិត្វា ឧប្បលនាលេ វិយ ឆិន្ទិត្វា មំសំ ខាទិត្វា គិលន្តិយោ អទ្ទសំ អយំ ចុទ្ទសមោ សុបិនោ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ លោកេ បរិហាយន្តេ អនាគតេយេវ វិបាកោ



ទីជំនុំសង្ឃ ពួកភិក្ខុ ក៏មិនឃើញភិក្ខុអ្នកមានសីលជាទីស្រឡាញ់ អ្នកគួរធ្វើសេចក្តីគោរពថា ជាសំខាន់ ក្នុងឋានៈផ្សេង ៗ ដូចពោលមកហើយ ទាំងពាក្យសំដីរបស់ភិក្ខុអ្នកមានសីល ជាទីស្រឡាញ់ទាំងនោះ គេមិនរាប់រកយកជាការងារអ្វីឡើយ ប្រៀបដូចជាការអណ្តែតទៅនៃដុំថ្មទាំងឡាយ ដូច្នោះ ។ ភ័យ សូម្បីមានសុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រ សូមទ្រង់ត្រាស់ព្រះសុបិនទី ១៤ បន្តទៀតចុះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញពពួកកង្កែបដែលមានខ្លួនតូច ៗ ប៉ុនផ្កាស្វាយ រត់ដេញខាំពស់វែកធំ ៗ ខាំសាច់ដាច់ដូចគេកាត់ទងឈូក ហើយក៏ស៊ីលេបទៅ នេះជាសុបិនទី ១៤ អ្វីជាផលនៃសុបិននេះ ព្រះអង្គ ? ។

មហាបពិត្រ ផលនៃសុបិនប្រការនេះ នឹងមានក្នុងអនាគតឯណោះ ក្នុងកាលលោកទ្រុឌទ្រោមចុះ ព្រោះថា ក្នុងគ្រានោះ

ភវិស្សតិ តទា ហិ មនុស្សា តិព្វរាគា ទុជ្ជាតិកា កិលេសានុវត្តកា ហុត្វា តរុណតរុណានំ អត្តនោ ភរិយានំ វសេ វត្តិស្សន្តិ គេហេ ទាសកម្មករាទយោបិ គោមហិទយោបិ ហិរញ្ញសុវណ្ណម្បិ សព្វំ តាសំយេវ អាយត្តំ ភវិស្សតិ អសុកំ ហិរញ្ញសុវណ្ណំ វា បរិច្ឆេទាទិជាតំ វា កហន្តិ វុត្តេ យត្ថ វា តត្ថ វា ហោតុ កឹ តុយ្ហមេវ ព្យាបារេន ត្វំ មយ្ហំ ឃរេ សន្តំ វា អសន្តំ វា ជានិតុកាមោ ជាតោសីតិ វត្វា នានប្បការេហិ អក្កោសិត្វា មុខសត្តីហិ កោដ្ដេត្វា ទាសចេដកេ វិយ អត្តនោ វសេ កត្វា អត្តនោ ឥស្សរិយំ



ពួកមនុស្សនឹងមានរាគចរិតខ្លាំងក្លា មានជាតិអាក្រក់ បណ្ដោយខ្លួន បណ្ដោយចិត្តទៅតាមអំណាចកិលេស និង ប្រព្រឹត្តទៅក្នុងអំណាចភរិយាក្មេង ៗ របស់ខ្លួន អ្នកមានទាសៈ កម្មករ ជាដើមក្ដី សត្វពាហនៈ មានគោ ក្របីជាដើមក្ដី មាស ប្រាក់ជាដើមក្ដី ដែលមាននៅក្នុងផ្ទះគ្រប់យ៉ាង នឹងតាំងនៅក្នុងការគ្រប់គ្រងរបស់ពួកនាងទាំងនោះ កាលពួកស្វាមីសួរដល់មាសប្រាក់ឯណោះ ៗ ថា នៅទីណា ឬសួរដល់ចំនួនរបស់របរផ្សេង ៗ មាននៅក្នុងទីណាក្ដី ពួកនាងទាំងនោះ នាំគ្នាឆ្លើយថា របស់ទាំងនោះនៅទីណាក៏ដោយចុះ ប្រយោជន៍អ្វីដែលអ្នកត្រូវត្រួតត្រាវា អ្នកចង់ដឹងវត្ថុដែលមាន និងមិនមាននៅក្នុងផ្ទះរបស់យើងដែរឬ ? ហើយជេរដោយប្រការផ្សេង ៗ ចាក់ដោតដោយលំពែង គឺ មាត់ ពួកបុរសក៏ធ្លាក់ចុះក្នុងអំណាចរបស់ស្ត្រីទាំងនោះ ដូចជាទាសៈ ឬខ្ញុំបម្រើ ពួកស្ត្រីទាំងនោះ ក៏តាំងនៅក្នុងភាពជាម្ចាស់ ជាធំតទៅ ប្រៀបបី

បវត្តេស្សន្តិ ឯវំ មធុកបុប្ផប្បមាណានំ មណ្ឌុកបោតិកានំ អាសីវិសេ កណ្ហសប្បេ គិលនកាលោ វិយ ភវិស្សតិ ឥតោនិទានម្បិ តេ ភយំ នត្ថិ បណ្ណរសមំ កថេហីតិ ។

ភន្តេ ទសហិ អសទ្ធម្មេហិ សមន្នាគតំ គាមគោចរំ កាកំ កាញ្ចនវណ្ណបណ្ណតាយ សុវណ្ណាតិ លទ្ធនាមេ សុវណ្ណរាជហំសេ បរិវារេន្តេ អទ្ទសំ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ អនាគតេ ទុព្វលរាជកាលេយេវ វិបាកោ ភវិស្សតិ អនាគតស្មឹ ហិ រាជានោ ហត្ថិសិប្បាទីសុ អកុសលា យុទ្ធេសុ អវិសារទា ភវិស្សន្តិ តេ អត្តនោ រជ្ជវិបត្តឹ អាសង្កមានានំ សមានជាតិកានំ កុលបុត្តានំ



ដូចជាពពួកសត្វកង្កែបដែលតូច ៗ ប៉ុនផ្កាស្វាយ ដេញខាំស៊ីពស់វែក ដែលមានពិសដ៏ពន្ទឹក ដូច្នោះ ។ ភ័យ សូម្បីមានសុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រទេ សូមទ្រង់ត្រាស់ប្រាប់និមិត្តទី ១៥ បន្តទៀតចុះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញហ្វូងស្ដេចហង្សមាសដែលមានឈ្មោះថា មាស ព្រោះមានរោមពណ៌មាស នាំគ្នាហែហមសត្វក្អែក ជាអ្នកប្រកបដោយអសទ្ធម្ម ១០ ប្រការ ត្រាច់ចររកស៊ីតាមស្រុក អ្វីជាផលនៃព្រះសុបិននេះ ព្រះអង្គ ? ។

មហាបពិត្រ ផលនៃសុបិននេះ ក៏នឹងមានក្នុងអនាគតដូចគ្នា ក្នុងសម័យរបស់ព្រះរាជាដែលទុព្វលនោះនោះឯង ព្រោះថាក្នុងកាលខាងមុខ ព្រះរាជាទាំងឡាយមិនច្លាតក្នុងសិល្បៈ មានសិល្បៈដំរីជាដើម មិនក្លៀវក្លាក្នុងយុទ្ធវិធី ព្រះរាជាមិនប្រទានភាពជាធំ ឲ្យដល់ពួកកុលបុត្តដែលមានជាតិស្មើគ្នា ជាអ្នកស្អប់-

ឥស្សរិយំ អទត្វា អត្តនោ បាទមូលិកានំ ន្ហាបកក-
ប្បកាទីនំ ទស្សន្តិ ជាតិគោត្តសម្បន្នា កុលបុត្តា រាជកុលេ
បតិដ្ឋំ អលភមានា ជីវិតំ កប្បេតុំ អសមត្ថា ហុត្វា
ឥស្សរិយេ ឋិតេ ជាតិគោត្តហីនេ អកុលីនេ ឧបដ្ឋហន្តា
វិចរិស្សន្តិ សុវណ្ណរាជហំសេហិ កាកស្ស បរិវារិតកាលោ
វិយ ភវិស្សតិ ឥតោនិទានម្បិ តេ ភយំ នត្ថិ សោឡសមំ
កថេហីតិ ។

ភន្តេ បុព្វេ ទីបិនោ ឯឡកោ ខាទន្តិ អហម្បន
ឯឡកេ ទីបិនោ អនុពន្ធិត្វា មុរុមុរាតិ ខាទន្តេ អទ្ទសំ អថញ្ញេ
តសា វកា ឯឡកេ ទូរតោវ ទិស្វា ភីតតសិតា ឧត្រា-



ខ្ពើមដល់ភាពវិបត្តិនៃរាជសម្បត្តិ មិនព្រះរាជទានដល់ពួកភ្នាក់ងារ
និងពួកជាងកាត់សក់ជាដើម ដែលនៅជិតបាទមូលរបស់ព្រះអង្គ
ពួកកុលបុត្តដែលសម្បូរណ៍ដោយជាតិ និងគោត្រ កាលមិនបាន
ទីពឹងអំពីរាជត្រកូល ក៏មិនអាចចិញ្ចឹមជីវិតបាន ក៏នាំគ្នាទៅអែប-
អប យកចិត្តយកថ្លើមដល់អ្នកដែលគ្មានត្រកូល មានជាតិ និង
គោត្រថោកទាបដែលមានអំណាចជាធំ ប្រៀបដូចជាពពួកហង្ស
មាស ធ្វើជាបរិវារតាមហែហមសត្វក្អែក ដូច្នោះ ។ ភ័យ សូម្បី
មានសុបិននេះ ក៏មិនមានដល់មហាបពិត្រ សូមទ្រង់ត្រាស់សុបិន
ទី ១៦ បន្តទៀតចុះ ។

បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលមុន ៗ សត្វខ្លាតែងខាំស៊ី
ពពែ តែខ្ញុំព្រះអង្គបានសុបិនឃើញហ្វូងពពែ នាំគ្នាដេញខាំពពួក
សត្វខ្លាស៊ីទៅវិញ ពេលនោះខ្លាដទៃ ៗ គឺ ខ្លាដំបង ខ្លាធំ ឃើញ
ពួកពពែពីចម្ងាយ ក៏តក់ស្លុតរន្ធត់ភ័យខ្លាចយ៉ាងខ្លាំង ហើយនាំគ្នា

សមប្បត្តា ហុត្វា ឯឡ្ហកានំ ភយា បលាយិត្វា គុម្ពគហនានិ បវិសិត្វា និលីយឹសុ ឯវាហំ អទ្ទសំ ឥមស្ស កោ វិបាកោតិ ។

ឥមស្សាបិ អនាគតេ អធម្មិករាជកុលេយេវ វិបាកោ ភវិស្សតិ តទា ហិ អកុលីនា រាជវល្លភា ឥស្សរា ភវិស្សន្តិ កុលីនា អប្បញ្ញាតា ទុគ្គតា តេ រាជវល្លភា រាជានំ អត្តនោ កថំ គាហាបេត្វា វិនិច្ឆយដ្ឋានាទីសុ ពលវន្តោ ហុត្វា កុលីនានំ បវេណិអាគតានិ ខេត្តវត្ថាទីនិ អម្ហាកំ សន្តកានិ ឯតានីតិ អភិយុញ្ជិត្វា តេសុ ន តុម្ហាកំ អម្ហាកន្តិ អាគន្ត្វា



រត់គេចចូលទៅកាន់គម្ពោតព្រៃ លាក់ខ្លួនពួនអាត្មា ព្រោះខ្លាចពួកពពែ ខ្ញុំព្រះអង្គបានឃើញយ៉ាងនេះ អ្វីជាផលនៃសុបិននេះ ព្រះ-អង្គ ? ។

មហាបពិត្រ ផលនៃសុបិននេះ ក៏មានក្នុងសម័យនៃព្រះ-រាជាអ្នកមិនតាំងនៅក្នុងធម៌ ក្នុងអនាគតដូចគ្នា ព្រោះថា ក្នុងគ្រានោះ ពួកអ្នកគ្មានត្រកូលចេះអែបអប ប្រចុបប្រចែងជាមួយព្រះ-រាជា ក៏នឹងបានជាធំ ពួកអ្នកមានត្រកូលក៏បាត់បង់កេរ្តិ៍ឈ្មោះទៅជាអ្នកក្រលំបាក ។ ពួកអ្នកប្រចុបប្រចែងទាំងនោះ នាំគ្នាធ្វើឲ្យព្រះរាជាទ្រង់ជឿជល់ពាក្យសំដីរបស់ខ្លួន នឹងតែងតាំងខ្លួនឲ្យមានអំណាចក្នុងនាទីរាជការ មានសាលាក្តីជាដើម ។ ពួកទាំងនោះក៏បាននាំគ្នារុករានយកដីធ្លីស្រែចម្ការសួនដំណាំជាដើម រហូតដល់របស់ពួកអ្នកមានត្រកូលទាំងឡាយ ថាកន្លែងទាំងនេះជារបស់ពួកយើង កាលពួកអ្នកមានត្រកូលទាំងនោះតវ៉ាថា មិនមែនជារបស់

វិនិច្ឆយដ្ឋានាទីសុ វិវទន្តេសុ វេត្តលតាទីហិ បហរាបេត្វា គីវាយំ គហេត្វា អបកឌ្ឍាបេត្វា អត្តនោ បមាណំ ន ជានាថ អម្ហេហិ សទ្ធឹ វិវទថ ឥទានិ វោ រញ្ញោ កថេត្វា ហត្ថបាទច្ឆេទនាទីនិ ការេស្សាមាតិ សន្តជ្ជេស្សន្តិ តេ តេសំ ភយេន អត្តនោ វត្ថូនិ តុម្ហាកំយេវ បេតានិ គណ្ហថាតិ និយ្យាទេត្វា អត្តនោ គេហានិ បវិសិត្វា ភីតា និបជ្ជស្សន្តិ បាបភិក្ខូបិ បេសលេ ភិក្ខូ យថារុចឹ វិហេឋេស្សន្តិ តេ បេសលា ភិក្ខូ បដិសរណំ អលភមានា អរញ្ញំ បវិសិត្វា គហនដ្ឋានេសុ



ពួកលោកទេ នេះជារបស់ពួកយើង ហើយនាំគ្នាមកប្តឹងសាលាកាត់ក្តីជាដើម ពួកជនអ្នកប្រចុបប្រចែងទាំងនោះ បានប្រាប់គ្នាឲ្យវាយនឹងរំពាត់ផ្តៅជាដើម ហើយរុញក្បាលចេញ ព្រមទាំងសំឡុតគំរាមកំហែងថា ពួកនេះមិនដឹងប្រមាណខ្លួន មករករឿងជាមួយពួកយើងផង ឥឡូវនេះយើងនឹងទៅទូលព្រះរាជា ឲ្យដាក់ព្រះរាជអាជ្ញាផ្សេង ៗ មានការកាត់ដៃ ជើង ជាដើម ។ ពួកអ្នកមានត្រកូលមានការខ្វបខ្វាចដល់ពួកអ្នកប្រចុបប្រចែងទាំងនោះ ក៏បានយល់ព្រមប្រគល់ដីធ្លីរបស់ខ្លួនថា ដីធ្លីទាំងនេះ បើជារបស់លោកក៏សូមលោកទទួលយកចុះ ហើយក៏នាំគ្នាត្រឡប់មកផ្ទះរបស់ខ្លួន សូម្បីដេក ក៏មានការភិតភ័យតាម ៗ គ្នា ។ សូម្បីពួកភិក្ខុដ៏ថោកទាបទាំងឡាយ ក៏នាំគ្នាបៀតបៀនភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ពួកភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងនោះ គ្មានទីពឹងពំនាក់អាស្រ័យ ក៏នាំគ្នាចូលទៅកាន់ព្រៃភ្នំក្រំថ្ម ពួនសម្ងំគេចខ្លួន ។

និលីយិស្សន្តិ ឯវំ ហីនជច្ចេហិ ចេវ បាបភិក្ខូហិបិ ច ឧបទ្ទុតានំ ជាតិមន្តានំ កុលបុត្តានញ្ចេវ បេសលានំ ភិក្ខូនញ្ច ឯឡកានំ ភយេន តសវកានំ បលាយនកាលោ វិយ ភវិស្សតិ ឥតោនិទានម្បិ តេ ភយំ នត្ថិ អយំ ហិ សុបិនោ អនាគតញ្ញេវ អារព្ភ តេ ទិដ្ឋោ ព្រាហ្មណា បន ន ធម្មសុធម្មតាយ តយិ សិនេហេន តំកថយឹសុ ពហុំ ធនំ លភិស្សាមាតិ អាមិសចក្ខុតាយ ជីវិតវុត្តឹ និស្សាយ កថយឹសូតិ ។

ឯវំ សត្ថា សោឡសន្នំ មហាសុបិនានំ និប្ផត្តឹ កថេត្វា ន ខោ មហារាជ ឯតរហិ ត្វញ្ញេវ ឥមេ សុបិនោ អទ្ទស បោរាណករាជានោបិ អទ្ទសំសុ ព្រាហ្មណាបិ តេសំ ឯវមេវ



ប្រការដែលកុលបុត្តអ្នកមានជាតិត្រកូលទាំងឡាយ និង ភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងនោះ ត្រូវពួកជនអាក្រក់ និង ភិក្ខុលាមកទាំងឡាយ ចូលទៅប្រទូសរ៉ាយយ៉ាងនេះ ក៏ដូចកាលដែលពួកខ្លាជំបង ខ្លាធំទាំងឡាយនាំគ្នារត់ ព្រោះខ្លាចពួកសត្វពពែដូច្នោះ ។ ភ័យ សូម្បីមានសុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រឡើយ ។ សុបិនទាំងនេះដែលមហាបពិត្របានឃើញហើយ ប្រារព្ធចំពោះតែអនាគតប៉ុណ្ណោះ ប៉ុន្តែពួកព្រាហ្មណ៍ មិនបានទាយសុបិននេះដោយត្រឹមត្រូវទេ គឺ ទស្សន៍ទាយព្រោះអាស្រ័យការចិញ្ចឹមជីវិត ព្រោះឃើញដល់អាមិសថា ពួកយើងនឹងបានទ្រព្យច្រើន ៗ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ព្យាករណ៍ដល់ផលនៃសុបិនធំ ៗ ទាំង ១៦ ប្រការ យ៉ាងនេះហើយ ទ្រង់ត្រាស់ថា មហាបពិត្រ មិនមែនមានតែក្នុងពេលនេះប៉ុណ្ណោះទេ ដែលមហាបពិត្របានឃើញសុបិនទាំងនេះ សូម្បីព្រះរាជាមុនៗ ក៏ទ្រង់បាន

ឥមេ សុបិនោ គហេត្វា យញ្ញមត្តកេ ទិបឹសុ តតោ បណ្ឌិតេហិ ទិន្ននយេនាគន្ត្វា ពោធិសត្តំ បុច្ឆឹសុ បោរាណកបណ្ឌិតាបិ នេសំ ឥមេ សុបិនោ កថេន្តា ឥមិនា និយាមេនេវ កថេសុន្តិ វត្វា តេន យាចិតោ អតីតំ អាហរិ ។

អតីតេ ពារាណសិយំ ព្រហ្មទត្តេ រជ្ជំ ការេន្តេ ពោធិសត្តោ ឧទិច្ចព្រាហ្មណកុលេ និព្វត្តិត្វា វយប្បត្តោ ឥសិបព្វជ្ជំ បព្វជិត្វា អភិញ្ញា ចេវ សមាបត្តិយោ ច និព្វត្តេត្វា ហិមវន្តប្បទេសេ ឈានកីឡំ កីឡន្តោ វិហរតិ ។ តទា ពារាណសិយំ ព្រហ្មទត្តោ ឥមិនាវ និយាមេន ឥមេ



ឃើញដូចគ្នាដែរ ។ សូម្បីពួកព្រាហ្មណ៍ ក៏កាន់យកសុបិននេះរាប់បញ្ចូលក្នុងយញ្ញពិធីដូចគ្នា លុះកាលជាខាងក្រោយ អាស្រ័យពាក្យណែនាំរបស់ពួកបណ្ឌិតនាំគ្នាក្រាបទូល ទើបសួរព្រះពោធិសត្វ សូម្បីបុរាណបណ្ឌិតទាំងឡាយ កាលទស្សន៍ទាយសុបិនទាំងនេះ ដល់ព្រះរាជាទាំងនោះ ក៏នាំគ្នាទស្សន៍ទាយទំនងដូចគ្នានេះឯង កាលព្រះបាទបសេនទិកោសលទូលអារាធនា ទើបព្រះបរមសាស្តា ទ្រង់នាំយករឿងក្នុងអតីតមកជាឧទាហរណ៍ ដូចតទៅនេះ ៖

ក្នុងអតីតកាល គ្រាព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងក្រុងពារាណសី ព្រះពោធិសត្វមានកំណើតក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ចម្រើនវ័យហើយ បានបួសជាតាបស ញុំាំងអភិញ្ញាសមាបត្តិឲ្យកើត បានសាកល្បងរិទ្ធនៅក្នុងហិមវន្តប្រទេស ក្នុងពេលនោះឯង នៅឯនគរពារាណសី ព្រះបាទព្រហ្មទត្ត ទ្រង់

សុបិនោ ទិស្វា ព្រាហ្មណេ បុច្ឆិ ។ ព្រាហ្មណា ឯវមេវ យញ្ញំ យជិតុំ អារភឹសុ ។ តេសុ បុរោហិតស្ស អន្តេវាសិកមាណវោ បណ្ឌិតោ ព្យត្តោ អាចរិយំ អាហ អាចរិយ តុម្ហេហិ មយំ តយោ វេទេ ឧគ្គណ្ហាបិតា ននុ តេសុ ឯកំ មារេត្វា ឯកស្ស សោត្ថិកម្មករណំ នាម នត្ថីតិ ។ តាត ឥមិនា ឧបាយេន អម្ហាកំ ពហុធនំ ឧប្បជ្ជិស្សតិ ត្វំ បន រញ្ញោ ធនំ រក្ខិតុកាមោ មញ្ញេតិ ។ មាណវោ តេនហិ អាចរិយ តុម្ហេ តុម្ហាកំ កម្មំ ករោថ ឧយ្យានំ អគមាសិ ។ តំ ទិវសមេវ ពោធិសត្តោបិ តំ



ឃើញសុបិននេះ ដោយទំនងដូចគ្នា ក៏មានព្រះតម្រាស់សួរដល់ពួកព្រាហ្មណ៍ ។ ពួកព្រាហ្មណ៍ ក៏ប្រារព្ធពិធីបូជាយ័ញ្ញយ៉ាងនេះដូចគ្នា ។ បណ្តាព្រាហ្មណ៍ទាំងនោះ បុរោហិតមានសិស្សជាបណ្ឌិតឆ្លាត ពោលនឹងអាចារ្យថា លោកអាចារ្យ គម្ពីរត្រៃវេទទាំង ៣ លោកអាចារ្យបានឲ្យខ្ញុំរៀនចប់ហើយ ក្នុងវេទទាំង ៣ គម្ពីរនោះ ប្រការដែលថា ការសម្លាប់មនុស្សម្នាក់ហើយ ធ្វើឲ្យកើតសិរីសួស្តីដល់មនុស្សម្នាក់ទៀត មិនមានឡើយ មិនមែនឬ ? , លោកអាចារ្យឆ្លើយថា អ្នកដ៏ចម្រើន ដោយឧបាយនេះ ទ្រព្យដ៏ច្រើននឹងកើតដល់ពួកយើង ចំណែកអ្នកមុខតែលំបាកនឹងរក្សាព្រះរាជ-ទ្រព្យ ទេដឹង ? មាណពពោលថា លោកអាចារ្យបើដូច្នោះ ពួកលោកចូរធ្វើការងាររបស់ពួកលោកទៅចុះ ខ្ញុំមិនធ្វើអ្វីក្នុងសំណាក់របស់ពួកលោកឡើយ ហើយក៏បានដើរចេញទៅរហូតដល់ព្រះ-រាជឧទ្យានក្នុងថ្ងៃនោះឯង ។ សូម្បីព្រះបរមពោធិសត្វ ក៏ដឹងហេតុ

ការណំ ញត្វា អជ្ជ មយិ មនុស្សបថំ គតេ មហាជនស្ស ពន្ធនា មោក្ខោ ភវិស្សតីតិ អាកាសេនាគន្ត្វា ឧយ្យានេ ឱតរិត្វា សុវណ្ណបដិមា វិយ មង្គលសិលាតលេ និសីទិ ។ មាណវោ ពោធិសត្តំ ឧបសង្កមិត្វា វន្ទិត្វា ឯកមន្តំ និសីទិត្វា បដិសណ្ឋារំ អកាសិ ។ ពោធិសត្តោបិ តេន សទ្ធឹ មធុ-រប្បដិសណ្ឋារំ កត្វា កឹ នុ ខោ មាណវ រាជា ធម្មេន រជ្ជំ ការេតីតិ បុច្ឆិ ។ ភន្តេ រាជា នាម ធម្មិកោ អបិច ខោ បន នំ ព្រាហ្មណា អតិដ្ឋេ បក្ខន្ទាបេន្តិ រាជា សោឡស សុបិនេ ទិស្វា ព្រាហ្មណានំ អារោចេសិ ព្រាហ្មណា យញ្ញំ យជិស្សាមាតិ អារទ្ធា កឹ នុ ខោ ភន្តេ អយំ នាម



នោះ ហើយគិតថា ថ្ងៃនេះ បើយើងទៅដល់កន្លែងមនុស្ស ការផុតពីការចាប់ចងនឹងមានដល់មហាជន ដូច្នេះហើយ ក៏ហោះតាមផ្លូវអាកាស មកចុះកន្លែងឧទ្យានអង្គុយលើផ្ទាំងថ្មដែលជាមង្គល ដូចរូបដែលឆ្លាក់ដោយមាសដូច្នោះ ។ មាណពចូលទៅរកព្រះពោ-ធិសត្វ សំពះហើយ អង្គុយក្នុងកន្លែងដ៏សមគួរមួយ នឹងធ្វើបដិសណ្ឋារព្រះពោធិសត្វ ។ សូម្បីព្រះពោធិសត្វ ក៏បានធ្វើបដិ-សណ្ឋារយ៉ាងពីរោះជាមួយគេ ហើយសួរថា ព្រះរាជាសោយរា-ជសម្បត្តិប្រកបដោយធម៌ហើយឬ មាណព ? មាណពបានពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះរាជានៅបានព្រះនាមថាធម្មិករាជនៅឡើយទេ ប៉ុន្តែថា ពួកព្រាហ្មណ៍កំពុងលួងលោមព្រះអង្គឲ្យដើរផ្លូវខុស ព្រះរាជាទ្រង់ឃើញព្រះសុបិន ១៦ ប្រការត្រាស់ប្រាប់ដល់ពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ពោលថា ពួកយើងនឹងត្រូវបូជាយ័ញ្ញ ហើយក៏រៀបចំការនោះភ្លាម លោកម្ចាស់ដ៏

ឥមេសំ សុបិនានំ និប្ផត្តឹតិ រាជានំ សញ្ញាបេត្វា តុម្ហាកំ មហាជនំ ភយា មោចេតុំ ន វដ្ដតីតិ ។ មយំ ខោ នាម មាណវ រាជានំ ន ជានាម រាជាបិ អម្ហេ ន ជានាតិ សចេ បន ឥធាគន្ត្វា បុច្ឆេយ្យ កថេយ្យាមស្ស មយន្តិ ។ មាណវោ អហំ ភន្តេ តំ អានេស្សាមិ តុម្ហេ មនាគមនំ ឧទិក្ខន្តា មុហុត្តំ និសីទថាតិ ពោធិសត្តំ បដិជានាបេត្វា រញ្ញោ សន្តិកំ គន្ត្វា មហារាជ ឯកោ អាកាសចារិកតាបសោ តុម្ហាកំ ឧយ្យានេ ឱតរិត្វា តុម្ហេហិ ទិដ្ឋសុបិនានំ និប្ផត្តឹ កថេស្សា-មីតិ តុម្ហេ បក្កោសតីតិ អាហ ។ រាជា តស្ស កថំ សុត្វា តាវទេវ មហន្តេន បរិវារេន ឧយ្យានំ គន្ត្វា តាបសំ



ចម្រើន សូមលោកម្ចាស់ធ្វើឲ្យព្រះរាជាទ្រង់យល់ផងថា ដែលឈ្មោះថា ផលនៃសុបិននេះ គឺ ជាយ៉ាងនេះ ហើយជួយឲ្យមហា-ជនផុតអំពីភ័យផង លោកម្ចាស់ ។ ព្រះពោធិសត្វពោលថា ម្នាលមាណព យើងមិនបានស្គាល់ព្រះរាជា ព្រះរាជាក៏មិនស្គាល់យើង បើព្រះអង្គមកសួរដល់ទីនេះ យើងនឹងប្រាប់ដល់ព្រះអង្គបាន ។ មាណពបានពោលថា ខ្ញុំនឹងយាងព្រះអង្គមក សូមលោកម្ចាស់មេត្តារង់ចាំការមករបស់ខ្ញុំត្រឹមតែមួយភ្លែតចុះ កាលបើសុំការអ-នុញ្ញាតពីព្រះពោធិសត្វហើយ ក៏ទៅកាន់ព្រះរាជដំណាក់ ក្រាបទូលថា បពិត្រមហារាជ តាបសអ្នកត្រាច់ចរតាមផ្លូវអាកាសមួយអង្គ បានចុះមកក្នុងឧទ្យានរបស់ព្រះអង្គ ហើយបានពោលថា នឹង ទស្សន៍ទាយផលនៃព្រះសុបិន ដែលព្រះអង្គទ្រង់ឃើញ កំពុងអង្គុយចាំព្រះអង្គហើយ ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់មណព នោះ ស្ដេចក៏ប្រញាប់ទៅកាន់ព្រះឧទ្យានភ្លាម ព្រមដោយបរិវារដ៏

វន្ទិត្វា ឯកមន្តំ និសិន្នោ បុច្ឆិ តុម្ហេ កិរ ភន្តេ មយា ទិដ្ឋសុបិនានំ និប្ផត្តឹ ជានាថាតិ ។ អាម មហារាជាតិ ។ តេនហិ កថេថាតិ ។ កថេមិ មហារាជ យថាទិដ្ឋេ តាវ សុបិនេ មំ សាវេហីតិ ។ សាធុ ភន្តេតិ រាជា

ឧសភា រុក្ខា គាវិយោ គាវា ច
អស្សោ កំសោ សិគាលី ច កុម្ភោ
បោក្ខរណី ច អបាកចន្ទនំ លាពូនិ
សីទន្តិ សិលា ប្លវន្តិ មណ្ឌូកិយោ
កណ្ហសប្បេ គិលន្តិ កាកំ សុវណ្ណា



ច្រើន ទ្រង់សំពះតាបសហើយ ប្រថាប់អង្គុយកន្លែងដ៏សមគួរមួយ មានព្រះតម្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន បានឮថា លោកម្ចាស់ជ្រាបនូវផលនៃសុបិនដែលខ្ញុំបានឃើញឬ ? ព្រះ-ពោធិសត្វពោលថា សូមថ្វាយព្រះពរមហាបពិត្រ អាត្មាភាពជ្រាប ។ ព្រះរាជាត្រាស់ថា បើដូច្នោះ សូមលោកម្ចាស់ទស្សន៍-ទាយចុះ ។ ព្រះពោធិសត្វពោលថា សូមថ្វាយព្រះពរមហាបពិត្រ អាត្មាភាពនឹងទស្សន៍ទាយថ្វាយ សូមមហាបពិត្រត្រាស់សុបិនតាមដែលទ្រង់បានឃើញឲ្យអាត្មាភាពស្តាប់មកចុះ ។ ព្រះរាជាត្រាស់ថា ប្រពៃហើយលោកម្ចាស់ដ៏ចម្រើន ទើបត្រាស់ថា ៖

គោឧសភរាជ ១ ឈើទាំងឡាយ ១ មេគោទាំងឡាយ ១ គោឈ្មោលទាំងឡាយ ១ សេះ ១ ថាសមាស ១ មេឆ្កែចចក ១ ក្អមទឹក ១ បោក្ខរណី ១ បាយឆៅ ១ ច័ន្ទក្រហម ១ ឃ្លោកលិច ១ ថ្មអណ្តែត ១ កង្កែបខាំពស់វែក ១ ហង្សមាសហែហមក្អែក ១

បរិវារយន្តិ តសា វកា ឯឡកានំ

ភយា ហីតិ ។

វត្វា បសេនទិកោសលរញ្ញោ កថិតនិយាមេនេវ សុបិនោ កថេសិ ។ ពោធិសត្តោបិ តេសំ ឥទានិ សត្ថារា កថិត-និយាមេនេវ វិត្ថារតោ និប្ផត្តឹ កថេត្វា បរិយោសានេ សយំ ឥទំ កថេសិ វិបរិយាសោ វត្តតិ នយិធមត្ថីតិ ។ តត្រាយ-មត្ថោ អយំ មហារាជ ឥមេសំ សុបិនានំ និប្ផត្តិ យំ បនេតំ តេសំ បដិឃាតត្ថាយ យញ្ញកម្មំ វត្តតីតិ វុត្តំ ហោតិ ។ កឹការណា ។ ឥមេសញ្ហិ និប្ផត្តិ នាម លោកស្ស



ខ្លាធំ ខ្លាដំបង ភ័យខ្លាចព្រោះពពែ ១ ដូច្នេះ ។

ហើយត្រាស់ប្រាប់សុបិន តាមនិយមដែលព្រះបាទបសេ-នទិកោសលត្រាស់ប្រាប់នោះឯង ។ សូម្បីព្រះពោធិសត្វ ក៏បានទស្សន៍ទាយផលនៃសុបិនទាំងនោះ ដោយពិស្ដារតាមទំនងដែលព្រះសាស្ដាទ្រង់ទស្សន៍ទាយក្នុងពេលនេះឯង ហើយក្នុងទីបំផុតបានថ្វាយព្រះពរដូច្នេះថា នឹងប្រព្រឹត្តទៅក្នុងកាលដែលលោកជិតចូលដល់សេចក្ដីវិនាស គឺ មិនមានក្នុងយុគនេះឡើយ ។

អត្ថាធិប្បាយក្នុងពាក្យនោះ មានដូច្នេះ គឺ មហាបពិត្រ ផលនៃព្រះសុបិនទាំងនោះមានដូច្នេះ គឺ ការបូជាយញ្ញដែលកំពុងប្រព្រឹត្តទៅ ដើម្បីកំចាត់អន្តរាយក្នុងព្រះសុបិនទាំងនោះ រមែងជាការប្រព្រឹត្តិខុសក្នុងធម្មនិយាម លោកអធិប្បាយថា រមែងប្រព្រឹត្តទៅផ្ទុយគ្នា ខុសអំពីការពិត ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ផលនៃសុបិនទាំងនេះ នឹងមានក្នុងកាលដែលលោកជិតនឹងវិនាស

វិបរិវត្តកាលេ អការណស្ស ការណន្តិ គហណកាលេ ការណស្ស អការណន្តិ ឆឌ្ឌនកាលេ អភូតស្ស ភូតន្តិ គណ្ហនកាលេ ភូតស្ស អភូតន្តិ ជហនកាលេ អលជ្ជីនំ ឧស្សន្នកាលេ លជ្ជីនញ្ច បរិហីនកាលេ ភវិស្សតិ នយិធ-មត្ថីតិ ឥទានិ បន តវ វា មម វា កាលេ ឥធ ឥមស្មឹ បុរិសយុគេ វត្តមានេ ឯតេសំ និប្ផត្តិ នត្ថិ តស្មា ឯតេសំ បដិឃាតាយ វត្តមានំ យញ្ញកម្មំ វិបល្លាសេន វត្តតិ អលន្តេន នត្ថិ តេ ឥតោនិទានំ ភយំ វា ឆម្ភិតត្តំ វាតិ ។ មហាបុរិសោ រាជានំ សមស្សាសេត្វា មហាជនំ ពន្ធនា



គឺ ក្នុងកាលផ្សេង កាន់យកប្រការដែលមិនមែនហេតុ ថាហេតុ ក្នុងកាលដែលលះបង់ហេតុចេញ ថាមិនមែនហេតុ ក្នុងកាលដែល កាន់យកប្រការដែលមិនពិត ថាពិត ក្នុងកាលដែលលះបង់ប្រការ ដែលពិតថា មិនពិត ។ ក្នុងកាលដែលពួកអលជ្ជី មានច្រើនឡើង និង ក្នុងកាលដែលពួកលជ្ជីមានការថយចុះ ក៏នឹងមិនមាននៅក្នុង យុគនេះ មានន័យថា ផលរបស់ព្រះសុបិនទាំងនេះ មិនមាននៅ ក្នុងពេលនេះ គឺ ក្នុងរជ្ជកាលរបស់មហាបពិត្រ ឬ ក្នុងសាសនា របស់តថាគតនេះ ក្នុងយុគនេះ គឺ ក្នុងជួរបុរសបច្ចុប្បន្ននេះ ព្រោះហេតុនោះការបូជាយ័ញ្ញដែលកំពុងប្រព្រឹត្តទៅ ដើម្បីកំចាត់ អន្តរាយនៃផលរបស់ព្រះសុបិនទាំងនេះ ទើបប្រព្រឹត្តទៅមិនត្រឹម ត្រូវ លើកការបូជាយ័ញ្ញនោះចេញចុះ ភ័យ ឬ សេចក្តីភ័យខ្លាច ដែលមានព្រះសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រ ។ ព្រះមហាបុរស បានធ្វើឲ្យព្រះរាជាធូរស្រាលព្រះទ័យ លះបង់

មោចេត្វា បុនាកាលេ ឋត្វា រញ្ញោ ឱវាទំ ទត្វា បញ្ចសុ សីលេសុ បតិដ្ឋាបេត្វា ឥតោ បដ្ឋាយ មហារាជ ព្រាហ្មណេហិ សទ្ធឹ ឯកតោ ហុត្វា បសុឃាតយញ្ញនាម មា យជីតិ ធម្មំ ទេសេត្វា អាកាសេនេវ អត្តនោ វស-នដ្ឋានមេវ អគមាសិ ។ រាជាបិ តស្ស ឱវាទេ ឋិតោ ទានាទីនិ បុញ្ញានិ កត្វា យថាកម្មំ គតោ ។

សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា សុបិនបច្ចយា តេ ភយំ នត្ថិ ហារេថ យញ្ញន្តិ យញ្ញំ ហារេត្វា មហា-ជនស្ស ជីវិតទានំ ទត្វា អនុសន្ធឹ ឃដេត្វា ជាតកំ



មហាជនចេញពីការចាប់ចង ហើយក៏បានហោះឡើងលើអាកាស ថ្វាយឱវាទដល់ព្រះរាជា ឲ្យតាំងនៅយ៉ាងមាំក្នុងសីលប្រាំ ហើយ ថ្វាយព្រះពរថា តាំងពីពេលនេះតទៅ មហាបពិត្រកុំរួមគិតជាមួយ ព្រាហ្មណ៍បូជាយ័ញ្ញ ដែលឈ្មោះថា បសុឃាតយ័ញ្ញ ( យ័ញ្ញសម្លាប់សត្វ ) តទៅទៀត លុះសម្តែងធម៌ហើយ បានត្រឡប់ទៅ កាន់លំនៅរបស់ខ្លួនតាមផ្លូវអាកាសនោះឯង ។ ចំណែកព្រះរាជា តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ទ្រង់ធ្វើបុណ្យ មានការឲ្យ ទានជាដើម ហើយស្តេចទៅតាមយថាកម្ម ។

ព្រះបរមសាស្តា លុះទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ត្រាស់ឲ្យព្រះបាទបសេនទិកោសលលះបង់ការបូជាយ័ញ្ញ ដោយ ព្រះពុទ្ធតម្រាស់ថា ព្រោះព្រះសុបិនជាបច្ច័យ ភ័យនឹងមិនមាន ដល់មហាបពិត្រទេ មហាបពិត្រចូរត្រាស់បង្គាប់ឲ្យលះបង់យ័ញ្ញ ចេញចុះ ព្រះរាជទានជីវិតទានដល់មហាជន ហើយទ្រង់បន្តអនុ-

សមោធានេតិ តទា រាជា អានន្ទោ អហោសិ មាណវោ សារីបុត្តោ តាបសោ បន អហមេវាតិ ។

បរិនិព្វុតេ បន ភគវតិ សង្គីតិការកា ឧសភាតិ-អាទីនិ តីណិ បទានិ អដ្ឋកថំ អារោបេត្វា លាវុនីតិអាទីនិ បញ្ច បទានិ ឯកំ គាថំ វត្វា ឯកនិបាតបាលឹ អារោ-បេសុន្តិ ។

( មហាសុបិនជាតកំ សត្តមំ )



សន្និប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាព្រះអានន្ទ ក្នុងកាលឥឡូវនេះ , មាណព បានមកជាព្រះសារីបុត្ត ចំណែក តាបស គឺ ជាតថាគត ដូច្នេះឯង ។

លុះកាលព្រះមានព្រះភាគ ស្តេចបរិនិព្វានហើយ ព្រះ-សង្គីតិកាចារ្យទាំងឡាយលើកបទទាំង ៣ មានឧសភាជាអាទិ៍ ឡើងកាន់អដ្ឋកថា ពោលបទទាំង ៥ មាន លាវុនិ ឡើងកាន់បាលី ឯកនិបាត ដោយប្រការដូច្នេះ ។

( ចប់អដ្ឋកថា មហាសុបិនជាតក )